ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ

# THE PROCESS OF COLLECTING INCOME TAX TO THE GENERAL DEPARTMENT OF TAXATION

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យ វ៉ាន់ដា
VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ

# THE PROCESS OF COLLECTING INCOME TAX TO THE GENERAL DEPARTMENT OF TAXATION

គ្រូណែនាំ៖ យាន ដារ៉ា

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់**
**អគ្គនាយកដ្ឋានពន្ធដារ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

យាន ដារ៉ា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យ វ៉ាន់ដា អស់រយៈពេល ៤ឆ្នាំមកនេះ ការសិក្សារួចមកក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនដែលពាក់ព័ន្ធ នឹងមុខវិជ្ជាគណនេយ្យ ជាពិសេស ក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈសំខាន់ដែរសម្រាប់ ទីផ្សារបច្ចុប្បន្នក្នុងនោះស្ថាប័នរដ្ឋក្តីឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យ ដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បាន បញ្ចូលនូវមុខជំនាញសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយរហូត ដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការ អនុវត្តការងារគណនេយ្យពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រម ទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុង ន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុម យើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ដំណើរ ការនៃការ ប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចង ក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាព នៃការប្រមូលពន្ធលើប្រាក់ចំណូល។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណាមួយនេះឡើងនឹងបានចូលរួម ចំណែកមួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀត ដែលមានគោល បំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអាន ទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះហើយក្រុមយើងខ្ញុំរីករាយនឹង ទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



ស្រីន ឡៃហ័រ
ID: B22/911



ខុន ចាន់ណារី
ID: B22/910



ទុទ្ធី លីហ្សា
ID: B22/908



ខុន លក្ខិណា
ID: B22/907



ស្លេះ សាហ្វីយ៉ះ
ID: B22/916

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **ឃាន ដារ៉ា** ជាគ្រូណែនាំដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញលើកទឹកចិត្តនិងអនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យ វ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណានេះក្រោមប្រធានបទស្តីអំពី "**ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ**" នេះគឺពិតជាស្នាដៃមួយរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥
**ហត្ថលេខាតំណាងក្រុម**



ស្រ៊ិន ឡៃហ៊័រ

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ក្រោយពីបានធ្វើការចុះកម្មសិក្សាលើប្រធានបទ ដំណើរការនៃការ ប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការស្វែងយល់ និងជាជំនួយស្មារតីបន្ថែមឱ្យកាន់តែស៊ីជម្រៅ និងមានន័យកាន់តែគ្រប់គ្រាន់។ ក្រុមយើងខ្ញុំក៏សូមលើកយកចំណុចសំខាន់ៗយកមកសង្ខេបឡើងវិញដើម្បីមានភាពងាយស្រួលក្នុងការស្វែងយល់។

អគ្គនាយកដ្ឋានពន្ធដារកម្ពុជា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៤ តាមរយៈការប្រព្រឹត្តិនូវច្បាប់ និងគោលការណ៍ដែលទាក់ទងនឹងការប្រមូលប្រាក់ពន្ធនៅក្នុងប្រទេស។ ហើយវាបានផ្តល់ឲ្យមានអំណាច និងកម្លាំងនៅក្នុងការប្រមូលប្រាក់ពន្ធ សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងការទទួលខុសត្រូវចំពោះការអនុវត្ត នឹងការផ្តល់ពន្ធត្រឹមត្រូវ។ ពន្ធដារចាប់ផ្តើមបង្កើតឡើងថ្មីៗ ពីព្រោះការផ្លាស់ប្តូរនៅក្នុងសេដ្ឋកិច្ចជាតិ និង ប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារបានជួយឲ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាកាន់តែមានស្ថេរភាព នឹង មានភាពកាន់តែប្រសើរឡើងនៅក្នុងការអនុវត្តន៍យ៉ាងត្រឹមត្រូវនៃការប្រមូលប្រាក់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦១ ដោយមានគោលបំណងក្នុងការគ្រប់គ្រង ការបង់ពន្ធ និងត្រួតពិនិត្យនិង នូវការអនុវត្តតាមច្បាប់ពន្ធក្នុងប្រទេសកម្ពុជា។ ការចាត់តាំងបុគ្គលិកនៅក្នុងអគ្គនាយក ដ្ឋានពន្ធដារ ត្រូវបានកំណត់ជាចម្បង ដើម្បីពង្រឹងការប្រមូលពន្ធនិង ធានានូវការគ្រប់គ្រងអំពើការប្រមូលពន្ធតាមច្បាប់ យ៉ាងតឹងរឹង។ពេលបច្ចុប្បន្នអគ្គនាយកដ្ឋានពន្ធដារ កំពុងតែធ្វើការកែរតម្រូវនូវប្រព័ន្ធពន្ធដារដើម្បីបង្កើនការចុះបញ្ជីពន្ធ និងជំរុញការកែប្រែបែបបទនៅក្នុងប្រព័ន្ធពន្ធដារ នឹងធានាបាននូវប្រសិទ្ធភាពបំផុតក្នុងការប្រមូលពន្ធ។

សរុបសេចក្តីមក ការប្រមូលពន្ធលើប្រាក់ចំណូល គឺពិតជាមានសារៈសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិណាស់ ពន្ធលើប្រាក់ចំណូលជាចំណូលសំខាន់មួយសម្រាប់រដ្ឋ ហើយកាន់តែមានតួនាទីសំខាន់នៅក្នុងការគាំទ្រចំណាយទៅលើសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ អ្វីដែលសំខាន់ក្នុងការរួមបញ្ចូលមានដូចជាការបង្កើតប្រភពចំណូលថវិការឱ្យរដ្ឋជួយជម្រុញល្បឿនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចហិរញ្ញវត្ថុ និងអាចទប់ស្កាត់ប្រជាពលរដ្ឋនៅក្នុងសង្គម។ ដើម្បីសម្រួលចំណូល និងការបែងចែកឡើងវិញនូវចំណូល រវាងបណ្តាលស្រទាប់វណ្ណៈផ្សេងៗគ្នានៅក្នុងសង្គម ជាទូទៅរដ្ឋាភិបាលបានបង្កើតពន្ធប្រយោលចំពោះប្រភេទទំនិញ ឬសេវាមួយចំនួន របស់មុខសញ្ញាណាដែលមានចំណូលខ្ពស់ ជំនួសឲ្យការយកពន្ធដោយផ្ទាល់។ វិធីសាស្ត្រនេះ ក្នុងវិស័យគ្រប់គ្រង់ និងវិស័យចិត្តសាស្ត្រឱ្យមានភាពងាយស្រួលនៅក្នុងការបានទទួលស្គាល់ ។

# មាតិកា

ទំព័រ

អារម្ភកថា ........ i
របានាសម្ព័នក្រុម ........ ii
សេចក្ដីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi

## ជំពូកទី១
## សេចក្ដីផ្ដើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំដែនកំណត់ ........ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី២
## ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ

២.១ ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ៤
២.១.១ និយមន័យពន្ធលើប្រាក់ចំណូល ........ ៤
២.១.២ ប្រវត្តពន្ធលើប្រាក់ចំណូល ........ ៤
២.១.៣ របបនៃពន្ធនិងវិធានគណនេយ្យ ........ ៥
២.២ ដំណើរការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ៦
២.២.១ និយមន័យពន្ធ ........ ៦
២.២.២ ប្រវត្តិនៃពន្ធ ........ ៧
២.២.៣ ប្រភេទនៃពន្ធ ........ ៧
២.៣ ការប្រមូលពន្ធលើប្រាក់ចំណូលផ្ដល់សារៈសំខាន់ដល់សេដ្ឋកិច្ចជាតិ ........ ៨
២.៣.១ និយមន័យសេដ្ឋកិច្ចជាតិ ........ ៨

២.៣.២ ប្រវត្តិនៃសេដ្ឋកិច្ចជាតិ........................................................................ ៨
២.៣.៣ ទ្រឹស្តីសេដ្ឋកិច្ចជាតិ ........................................................................ ៩

## ជំពូកទី៣
## ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ

៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ ........................................................................ ១១
៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ........................................................................ ១១
៣.១.២ បេសកកម្ម ទស្សនវិស័យ និងគោលដៅរបស់ពន្ធដារ ........................................ ១៣
៣.១.៣ រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ........................................................................ ១៥
៣.២ ដំណើការនៃការប្រមូលពន្ធលើប្រាក់ចំណូល........................................................................ ១៥
៣.២.១ ការចុះបញ្ជីជាអ្នកជាប់ពន្ធ ........................................................................ ១៥
៣.២.២ អត្រាពន្ធលើប្រាក់ចំណូល........................................................................ ១៩
៣.២.៣ ការដាក់ស្នើលិខិតប្រកាសពន្ធ ........................................................................ ២៦
៣.២.៤.ការបង់ប្រាក់ពន្ធ ........................................................................ ២៩
៣.២.៥.អ្នកជាប់ពន្ធត្រូវអនុវត្តន៍ច្បាប់ ........................................................................ ២៩
៣.៣ សារៈសំខាន់ការប្រមូលពន្ធលើប្រាក់ចំណូល........................................................................ ៣១
៣.៣.១ អត្ថប្រយោជន៍នៃការប្រមូលពន្ធលើប្រាក់ចំណូល ........................................ ៣២
៣.៣.២ លទ្ធផលសរុបពីការប្រមូលពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ.................................. ៣២

## ជំពូកទី៤: វិភាគទៅលើចំណុចខ្លាំងនិងចំណុចខ្សោយ

៤.១ ការវិភាគទៅលើចំណុចខ្លាំង........................................................................ ៣៣
៤.២ ការវិភាគទៅលើចំណុចខ្សោយ ........................................................................ ៣៣

## ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........................................................................ ៣៥
៥.២ ការផ្តល់អនុសាសន៍ ........................................................................ ៣៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្ដីផ្ដើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថាគ្រប់បណ្ដាលប្រទេសទាំងអស់មានការរីកចម្រើន និងអភិវឌ្ឍន៍សុទ្ធសឹងតែគ្រប់វិស័យ ដោយមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ សហគ្រិន អ្នកវិនិយោគ និងរាជរដ្ឋាភិបាល។ កាលណាប្រទេសជាតិមួយ មានច្បាប់ទម្លាប់ត្រឹមត្រូវប្រទេសនោះ និងមានការរីកចម្រើន និងអភិវឌ្ឍន៍ដល់គោលដៅនៅក្នុងការរីកចម្រើនបានទាំងនោះសុទ្ធសឹងតែមានការទាមទារប្រភពប្រាក់ចំណូល ដែលទទួលបានពីការប្រមូលពន្ធដើម្បីយកទៅអភិវឌ្ឍន៍ និងពង្រឹងសេដ្ឋកិច្ចជាតិរបស់ប្រទេសខ្លួនឱ្យកាន់តែរឹងមាំ។

ជាក់ស្ដែងយើងសង្កេតឃើញថា ប្រទេសកម្ពុជាមានការរីកចម្រើនឡើងដោយមានការជ្រោមជ្រែង និងចូលរួមពីសំណាក់ វិស័យសេដ្ឋកិច្ច វិស័យសុខាភិបាល វិស័យទេសចរណ៍ និងជាពិសេសគឺវិស័យពន្ធដារ។ កត្តាដែលរាជរដ្ឋាភិបាលមានតម្រូវការប្រភពចំណូល គឺមានការជ្រោមជ្រែងទៅលើវិស័យពន្ធដារ ដើម្បីឱ្យប្រទេសកម្ពុជាមានការរីកចម្រើន និងអភិវឌ្ឍន៍។ ហេតុដូចនេះ ទើបរាជរាជ្ញាភិបាលបានដាក់គោលនយោបាយឈ្នះឈ្នះ និងយុទ្ធសាស្ត្រចតុកោណ ដើម្បីលើកស្ទួយលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការទាមទាររកចំណូលនៅក្នុងប្រទេសឱ្យមានភាពរីកដុះដាលគ្រប់វិស័យកាន់តែប្រសើរឡើង។

ការអនុវត្តការប្រមូលពន្ធនៅគ្រប់បណ្ដាលប្រទេសទាំងអស់មាន ការរីកដុះដាល់ឡើងនិងប្រជាជនមានការយល់ដឹងឡើងតាមសម័យកាលនៃការអភិវឌ្ឍន៏ប្រទេស។ ជាក់ស្ដែង ដំណើរការនៃការប្រមូលពន្ធនៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែមានភាពងាយស្រួលឡើងតាមរយៈការប្រមូលពន្ធតាមប្រព័ន្ធបច្ចេកវិទ្យា និងកើតមានសហគ្រាស ក្រុមហ៊ុនពាណិជ្ជកម្ម ក្រុមហ៊ុនសេវាកម្ម។ ល ។ គ្រប់សហគ្រាសដែលធ្វើអាជីវកម្ម ផ្ដល់សេវាកម្ម និងផ្គត់ផ្គង់ទំនិញត្រូវមានកាតព្វកិច្ចបង់ពន្ធផ្សេងៗទៅតាមប្រភេទអាជីវកម្មក្នុងចំណោមពន្ធទាំងនោះក៏រួមមាន **ពន្ធលើប្រាក់ចំណូល** ដែរដើរតួរយ៉ាងសំខាន់ក្នុងការប្រមូលពន្ធក៏ជាប្រធានបទដែលបកស្រាយនៅក្នុងសារណាបញ្ចប់ការសិក្សា។ការប្រមូលពន្ធទាំងអស់មិនមែនមានទម្រង់ដូចគ្នាទាំងអស់នោះទេហេតុនេះហើយទើបធ្វើឱ្យក្រុមនាងខ្ញុំលើកឡើងដើម្បីមកធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ"**ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ "**

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

យោងតាមការសិក្សាស្រាវជ្រាវរបស់ក្រុមនាងខ្ញុំ ដែលបានបង្កើតឡើងក្នុងគោលបំណងសិក្សាស្រាវជ្រាវយល់ដឹងខ្លឹមសារទៅលើដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលអាចជាថ្នូរ ក្នុងការមានភាពងាយស្វែងរកដល់ការសិក្សាស្រាវជ្រាវឱ្យកាន់តែយល់ដឹងច្បាស់អំពី ការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលជាការឆ្លើយតបទៅនិងសំណួរៈ

១. តើដំណើរការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារប្រព្រឹត្តិទៅដូចម្ដេច ?

២. តើការប្រមូលពន្ធលើប្រាក់ចំណូលបានផ្ដល់សារៈសំខាន់អ្វីខ្លះដល់ សេដ្ឋកិច្ចជាតិ ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវដើម្បីយល់ដឹងអំពីច្បាប់ពន្ធដារនៅកម្ពុជា ដែលទាក់ទងទៅនឹងដំណើរការប្រមូលពន្ធលើប្រាក់ចំណូល។ មួយផ្នែកទៀត គឺអាចពង្រីកគំនិតចំណេះដឹងនៅក្នុង ការសរសេរអត្ថបទនេះឱ្យបានកាន់តែស៊ីជម្រៅនឹងច្បាស់ទៅលើច្បាប់នៃការប្រមូលពន្ធពីប្រជាពលរដ្ឋ ក្រុមហ៊ុនសេវាកម្ម ឬអាជីវកម្មផ្សេងៗទៀត។ ខាងក្រោមនេះ ជាគោលបំណងសិក្សាស្វែងយល់៖

-យល់ដឹងអំពីច្បាប់សារពើពន្ធក្នុងព្រះរាជាណាចក្រកម្ពុជា

-យល់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

-យល់អំពីការប្រមូលពន្ធលើប្រាក់ចំណូលរបស់ពន្ធដារ

-ស្វែងយល់ពីកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

តាមច្បាប់សារពើពន្ធ នៅកម្ពុជាយើងសង្កេតឃើញថា មានប្រភេទពន្ធដារច្រើនខុសប្លែកពីគ្នាទៅតាមប្រភេទពន្ធនីមួយៗ។ ដោយសារតែតាមច្បាប់សារពើពន្ធមានភាពធំទូលំទូលាយ និងត្រូវការដើម្បីទាមទារឱ្យយើងមានពេលវេលាច្រើនគ្រប់គ្រាន់ ក្នុងការសិក្សាឱ្យបានកាន់តែស៊ីជម្រៅទាក់ទងនឹងដំណើរការពន្ធលើប្រាក់ចំណូល។ ហេតុដូចនេះហើយ ទើបក្រុមយើងខ្ញុំបានលើកយកតែពន្ធសំខាន់តែ១៨ ប្រភេទប៉ុណ្ណោះ ក្នុងដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់ពន្ធដារយកមកសិក្សាស្រាវជ្រាវ។ ដែរមានទីតាំងស្ថិតនៅអគារកែងមហាវិថីសហព័ន្ធរុស្ស៊ី(១១០) និងម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ចំណែកឯនៅក្នុងអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានបង្កើតឡើងជាយូរឆ្នាំមកហើយ ដូច្នេះទើបពួកយើងបានលើកយកនៅក្នុងឆ្នាំ២០២៣ មកបកស្រាយនឹងប្រមូលទិន្នន័យមកដើម្បីធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ប្រើប្រាស់តាមវិធីសាស្ត្របែបគុណវិស័យ សម្រាប់រៀបរាប់ពីប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការប្រមូលទិន្នន័យធ្វើឡើងបានដោយផ្អែកទៅលើឯកសារដែរពាក់ព័ន្ធ និងច្បាប់ស្តីសារពើរបស់ពីអគ្គនាយកដ្ឋានពន្ធដារដើម្បីបញ្ជាក់អំពី ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ការស្រាវជ្រាវនេះ បានប្រើប្រាស់តាមវិធីសាស្ត្របែបគុណវិស័យ ដូចជាការធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យដែលមានស្រាប់ ដែលមាននៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យវ៉ាន់ដារ និងសៀវភៅឈ្មោះ នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ(ទំព័រ២១) សៀវភៅច្បាប់ស្តីពីសារពើពន្ធ និងតាមប្រព័ន្ធអ៊ីនធឺណេត។

សម្រាប់សំណួរស្រាវជ្រាវទី២ ៖ ការស្រាវជ្រាវនេះ ប្រើប្រាស់តាមវិធីសាស្ត្របែបគុណវិស័យ ដូចជាធ្វើឡើងតាមរយៈការដកស្រង់ទិន្នន័យដែលមានស្រាប់ដូចជា សៀវភៅច្បាប់ស្តីពីសារពើពន្ធ ប្រកាសស្តីពីប្រាក់ចំណូលប្រចាំឆ្នាំ តាមរយៈលីងរបស់អគ្គនាយកដ្ឋានពន្ធដារ តាមច្បាប់និងបទប្បញ្ញត្តិនៅប្រកាសលេខ០៩៨ និង៥៩៨ និងស្វែងរកតាមរយៈគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារប្រព័ន្ធអ៊ីនធឺណេត។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ គឺដើម្បីបង្កើននូវចំណេះជំនាញ ក្នុងការសិក្សារៀនសូត្រ ចេះគិតពិចារណាឱ្យកាន់តែមានភាពស៊ីជម្រៅ។ សារៈសំខាន់នៅក្នុងការស្រាវជ្រាវមានដូចជា៖

- ការពង្រឹង និងពង្រីកនូវចំណេះដឹងដល់និស្សិតឲ្យមានភាពទូលំទូលាយ
- ការស្រាវជ្រាវគឺធ្វើឲ្យយើងទទួលបាននូវចំណេះដឹងថ្មីៗ សម្រាប់ការសិក្សារបស់ខ្លួន
- អាចផ្តត់ផ្គង់ចំណាយសំខាន់ៗរបស់ប្រទេសជាតិ
- អភិវឌ្ឍន៍ទៅលើវិស័យអប់រំនិងវិស័យសុខាភិបាល
- ផ្តល់យោបល់ឲ្យស្ថាប័នដើម្បីកែលម្អប្រព័ន្ធប្រមូលពន្ធឲ្យមានប្រសិទ្ធភាព
- បង្កើនការយល់ដឹងសាធារណៈ និងគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិ
- បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ គ្រូបង្រៀននិងកសាងសាលារៀន មន្ទីរពេទ្យ ស្ពាន ថ្នល់។ល។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ យើងបានបែងចែកជា ផ្នែកនីមួយៗដូចខាងក្រោម៖

- ជំពូកទី១៖ សេចក្តីផ្តើម សិក្សាទៅលើលំនាំស្រាវជ្រាវ ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវសារៈសំខាន់ និងវិធីសាស្ត្រនៃការចងក្រងអត្ថបទនេះឡើង។
- ជំពូកទី២៖ ក្នុងជំពូកនេះបង្ហាញឱ្យឃើញនៅមូលដ្ឋានអំពីលក្ខណៈទូទៅនៃដំណើរការប្រមូលពន្ធប្រាក់ចំណូលមូលហេតុនៃការប្រមូលពន្ធលើប្រាក់ចំណូល និងសារៈសំខាន់ការប្រមូលពន្ធប្រាក់ចំណូល រួមមាននិយមន័យទ្រឹស្តីប្រភពនិង ប្រវត្តិរបស់ពន្ធលើប្រាក់ចំណូលផងដែល។
- ជំពូកទី៣៖ បង្ហាញអំពីស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ សិក្សាអំពីរបបគតិយុត្តពន្ធលើប្រាក់ចំណូលរបៀបគណនាពន្ធប្រាក់ចំណូល ការបំពេញលិខិលប្រកាសនិតិវិធីនៃការដាក់លិខិតប្រកាស។
- ជំពូកទី៤៖ បង្ហាញអំពីចំណុចខ្លាំងនិងចំណុចខ្សោយ។
- ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ បន្ទាប់មកនិងបញ្ចេញមតិផ្ទាល់ខ្លួនសម្រាប់ការកែសម្រួលរាល់ចំណុចខ្វះខាត។

# ជំពូលទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូល

## ២.១ ដំណើការនៃការប្រមូលពន្ធលើប្រាក់ចំណូល

### ២.១.១ និយមន័យពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូល៖ គឺជាពន្ធដែលដាក់លើបុគ្គល ឬអង្គភាពទាក់ទងនឹងប្រាក់ចំណូល ឬប្រាក់ចំណេញដែលទទួលបានដោយពួកគេ។ ពន្ធលើប្រាក់ចំណូល ជាទូទៅត្រូវបានគណនាជាផលិតផលនៃអត្រាពន្ធដងនៃប្រាក់ចំណូលជាប់ពន្ធ។ អត្រាពន្ធអាចប្រែប្រួលតាមប្រភេទ ឬលក្ខណៈរបស់អ្នកជាប់ពន្ធ និងប្រភេទចំណូល[1]។

ពន្ធលើប្រាក់ចំណូល៖ ត្រូវបានកំណត់លើអ្នកជាប់ពន្ធនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូល ប្រភពបរទេស។ សម្រាប់អ្នកជាប់ពន្ធអនិវាសនជន៍ ពន្ធលើប្រាក់ចំណូលកំណត់តែលើប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ[2]។

ពន្ធលើប្រាក់ចំណូល៖ គឺជាកាតព្វកិច្ចរបស់អ្នកជាប់ពន្ធនិវាសនជនចំពោះ ប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស និងជាកាតព្វកិច្ចរបស់អ្នកជាប់ពន្ធអនិវាសនជន ចំពោះប្រាក់ចំណូលប្រភពកម្ពុជា។

ពន្ធលើប្រាក់ចំណូល៖ គឺជាពន្ធរបស់រដ្ឋាភិបាលលើប្រាក់ចំណូលរបស់បុគ្គល និងអាជីវកម្ម។ ថវិកាដែលប្រមូលបានរួមចំណែកដល់សេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ។

ពន្ធលើប្រាក់ចំណូល៖ គឺជាប្រភេទពន្ធប្រចាំឆ្នាំ ដែលត្រូវប្រកាសបង់ពន្ធ ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា នៃឆ្នាំជាប់ពន្ធបន្ទាប់ ចំពោះ ប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូល ប្រភពបរទេសរបស់បុគ្គលនិវាសនជន និងប្រាក់ចំណូលប្រភពកម្ពុជាសម្រាប់បុគ្គលអនិវាសនជន។

ពន្ធលើប្រាក់ចំណូល៖ គឺជាប្រាក់ចំណូលសុទ្ធដែលបានមកពី លទ្ធផលសរុបទាំងអស់នៃប្រតិបត្តិការអាជីវកម្ម គ្រប់ប្រភេទ រួមបញ្ចូលទាំងចំណេញមូលធនដែលសម្រេចបានក្នុងពេលប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់ អាជីវកម្ម ប្រាក់ឈ្នួល នឹងសំណងផ្សេងៗ ព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មរិធីយ៉ាងរាប់ទាំងអចលទ្រព្យ[3]។

### ២.១.២ ប្រវត្តពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូល មានប្រភពពីសកម្មភាពអាជីវកម្មរបស់បុគ្គលអនិវាសនជនតាមគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកជាប់ពន្ធនិវាសនជននៅកម្ពុជា និងអ្នកជាប់ពន្ធអនិវាសនជនអាចមានប្រាក់ចំណូល។

យោងទៅតាមមាត្រា៣៣ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ នៅក្នុងស្តីបទប្រភពនៅកម្ពុជាត្រូវបានចែកជាពីរ ប្រាក់ចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពបរទេស៖

[1] ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ. (២០២៣). *សេចក្តីប្រកាសពន្ធលើប្រាក់ចំណូលឆ្នាំ.* ទំព័រទី៤. ប្រការ៧.

[2] ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ. ថ្នាលធុរកិច្ច. (ឆ្នាំ២០២២). *ពន្ធលើប្រាក់ចំណូល.* Retrieved from https://business.gov.kh/

[3] អគ្គនាយកដ្ឋានពន្ធដារ. (ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣). *ពន្ធលើប្រាក់ចំណូល.* Retrieved from https://www.tax.gov.kh/km/content-detail/ab8WB7716349947443

**+ប្រាក់ចំណូលប្រភពកម្ពុជា**

១. ការប្រាក់ដែលបង់ដោយសហគ្រាសនិវាសនជន ឬក្រុមអាជីវកម្ម និវាសនជន ឬស្ថាប័នរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

២. ភាគលាភដែលបានបែងចែកដោយសហគ្រាសនិវាសនជន

៣. ប្រាក់ចំណូលពីការធ្វើអាជីវកម្ម ឬសេវាកម្មដែលបាននៅក្នុង ព្រះរាជាណាចក្រកម្ពុជា

៤. ប្រាក់ចំណូលពីការគ្រប់គ្រង និងសេវាបច្ចេកទេសដែលបានទូទាត់ ដោយបុគ្គលនិវាសនជន

៥. ប្រាក់ចំណូលដែលបានមកពីចលនទ្រព្យឬអចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៦. ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់ទ្រព្យសកម្មអរូបីដែលបានទូទាត់តាមបុគ្គលនិវាសនជន ឬបុគ្គលអនិវាសនជនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៧. ផលចំណេញពីការលក់អចលនទ្រព្យ ឬពីការផ្ទេរផលប្រយោជន៍ណាមួយ នៃអចលនទ្រព្យដែលមានតាមទីតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៨. ផលចំណេញពីការលក់អចលនទ្រព្យដែលជាចំណែកនៃទ្រព្យ អាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍របស់របស់អ្នកជាប់ពន្ធអនិវាសនជននៅ ក្នុងព្រះរាជាណាចក្រកម្ពុជា

៩. បុព្វលាភបានពីធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើហានិភ័យនៅក្នុង ព្រះរាជាណាចក្រកម្ពុជា

១០. ប្រាក់ចំណូលពីសកម្មភាពអាជីវកម្មរបស់បុគ្គលអនិវាសនជនតាម រយៈគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**+ប្រាក់ចំណូលប្រភពបរទេស**

រាល់ប្រាក់ចំណូលដែលមិនមែនជាប្រាក់ចំណូលប្រភពកម្ពុជាដូចមានចែងក្នុងមាត្រា៣៣ណៃច្បាប់នេះត្រូវចាត់ទុកជាប្រាក់ចំណូលប្រភពបរទេស[4]។

### ២.១.៣ របបនៃពន្ធនិងវិធានគណនេយ្យ

របបកំណត់ពន្ធនិងវិធានគណនេយ្យត្រូវបានកំណត់ដូចខាងក្រោម៖

១. របបកំណត់ពន្ធនៃព្រះរាជាណាចក្រកម្ពុជា ជារបបស្វ័យប្រកាសដែលតម្រូវឱ្យអ្នកជាប់ពន្ធដែលធ្វើការ គណនា ប្រាក់ពន្ធនិងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធដោយខ្លួនឯង។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបានចែកជា៣(បី)ប្រភេទ គឺ អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ។

២. វិធានគណនេយ្យសម្រាប់អ្នកជាប់ពន្ធដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវបានកំណត់ដូចខាងក្រោម៖

ក. អ្នកជាប់ពន្ធតូចត្រូវប្រើវិធានគណនេយ្យសាមញ្ញ។

---

[4] អគ្គនាយកដ្ឋានពន្ធដារ. (ឆ្នាំ២០២៣). *ច្បាប់ស្ដីពីសារពើពន្ធ*. ទំព័រទី១៧។

ខ. អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំ ត្រូវប្រើវិធានគណនេយ្យតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ ប្រាក់ចំណូល ត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីជាប្រាក់ចំណូលនោះបានទូទាត់ឬមិនទាន់ទូទាត់ក្តី។ ការកាត់កងចំណាយ ណាមួយដែលអាចធ្វើទៅបាន លុះត្រាតែហេតុការណ៍បញ្ជាក់ នូវបន្ទុករបស់អ្នកជាប់ពន្ធដែលបានកើតឡើងពីលទ្ធផលនៃសកម្មភាពសេដ្ឋកិច្ច ដែលជាប់ទាក់ទិនដល់ខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់។

គ.របបកំណត់ពន្ធ និងវិធានគណនេយ្យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[5]។

## ២.២ ដំណើរការប្រមូលពន្ធលើប្រាក់ចំណូល

### ២.២.១ និយមន័យពន្ធ

ពន្ធ៖ គឺជាបន្ទុក់របស់ប្រជាពលរដ្ឋបង់ចូលថវិការជាតិប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋជាចាំបាច់។

ពន្ធ៖ គឺជាអាករដែលប្រជានិករត្រូវបង់តាមការកំណត់ ឬជាប្រាក់កាក់ដែលប្រមូលពីបុគ្គលឯកជននានា តាមរយៈអំណាចសាធារណៈជាលក្ខណៈស្ថាពរនិងគ្មានអ្វីជាថ្នូរ ក្នុងគោលបំណងដើម្បីបំពេញបន្ទុកសាធារណៈ។

ពន្ធ៖ គឺជាវិភាគទានមានលក្ខណៈកាតព្វកិច្ច(ចាប់បង្ខំ) ដើម្បីឲ្យស្របតាមច្បាប់កំណត់ដែលអ្នកជាប់ពន្ធ មិនថារូបវន្តបុគ្គល និង នីតិបុគ្គលឡើយត្រូវតែបង់ជូនរដ្ឋ។

ពន្ធ៖ គឺជាការបង្ខិតបង្ខំ ឬជាការចាំបាច់ដោយខានពុំបាន ដែលរដ្ឋត្រូវតែដក ឬប្រមូល ផ្អែកលើមូលដ្ឋានដែលកំណត់ដោយច្បាប់ និងមានទិសដៅបំពេញរាល់ការប្រើប្រាស់របស់រដ្ឋ។ តាមការស្រាវជ្រាវ ការកកើតពន្ធឬទ្រឹស្តីទាក់ទងនិងពន្ធ គេរកឃើញថា បានកើតឡើងស្របជាមួយនឹងការកកើត នៃការប្រមូលផ្តុំគ្រប់គ្រងដំបូង និងនៅពេលដែលមានការកើតចេញឡើងនូវទម្រង់អង្គការចាត់តាំងនៃមនុស្ស។

ពន្ធ៖ គឺជារូបភាពមួយនៃការបែងចែកឡើងវិញ នូវចំណូលជាតិដែលរដ្ឋបានប្រើប្រាស់ ដើម្បីចលនាមួយផ្នែកចំណូលរបស់បណ្តាអង្គការចាត់តាំងសេដ្ឋកិច្ច (ក្រុមហ៊ុនសហគ្រាស...) និងរបស់ពលរដ្ឋ ដើម្បីបម្រើតម្រូវការរួមដល់អង្គភាពទាំងមូល។

ពន្ធ៖ គឺជាឧបករណ៍របស់រាជរដ្ឋាភិបាលដែលបង្កើតឡើង ដើម្បីកៀរគរចំណូលចូលថវិកាជាតិសម្រាប់ពន្ធ គឺជាកាតព្វកិច្ចរបស់បុគ្គលគ្រប់រូប ក្នុងការបង់ជាប្រាក់ ឬទំនិញទៅឱ្យរដ្ឋដោយមិនស្ម័គ្រចិត្ត។ ដើម្បីថែរក្សានូវផលប្រយោជន៍សាធារណៈទាំងនោះចាំបាច់ត្រូវទាមទារឱ្យមានការចូលរួមពីសំណាក់មហាជន[6]។

[5] អគ្គនាយកដ្ឋានពន្ធដារ. (ឆ្នាំ២០២៣). *ច្បាប់ស្តីពីសារពើពន្ធ* . ទំព័រទី៦ មាត្រាទី៦

[6] អគ្គនាយកដ្ឋានពន្ធដារ. ច្បាប់ពន្ធនៅកម្ពុជា. *ការណែនាំអំពីពន្ធដា.* ទំព័រ៣

### ២.២.២ ប្រវត្តិនៃពន្ធ



ក្នុងរជ្ជកាលសម័យកាលអាណានិគមបារាំងឆ្នាំ(១៨៦៣-១៩៥៣) ប្រទេសកម្ពុជាស្ថិតនៅក្រោមអាណានិគមនិយមបារាំងអស់ជិត១ សតវត្សដោយគិតចាប់ពីឆ្នាំ១៨៦៣ រហូតដល់ ពេលទទួលឯករាជ្យនៅឆ្នាំ ១៩៥៣។ ក្រោយពីទទួលបានឯករាជ្យ វិញនាថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ កម្ពុជាបានទទួលនូវផលវិបាកបន្តិចបន្តួចនៅក្នុងការត្រឡប់ទៅអនុវត្តច្បាប់ដើមនាសម័យបុរាណវិញ។ មិនយូរប៉ុន្មាន ចាប់តាំងពីពេលនោះមកសេដ្ឋកិច្ចនៅកម្ពុជាក៏មិនបានរីកចម្រើន គួរកត់សម្គាល់នោះទេ។ នៅកំឡុងពេលនោះ បារាំង បានធ្វើការប្រមូលប្រាក់ពន្ធ ដោយមានប្រសិទ្ធិភាព ប៉ុន្តែចាប់តាំងពីពេលនោះ មករហូតដល់ បច្ចុប្បន្ននេះយើងសង្កេតឃើញថាកម្ពុជា មានច្បាប់ពន្ធដារបែបទំនើប និងមានការរីកចម្រើនល្អមជាអាទិ៍ ច្បាប់ស្តីពីសារពើពន្ធត្រូវបានបង្កើតឡើងនាឆ្នាំ១៩៩៧ និងបទបញ្ញត្តិផ្សេងៗទៀត ដែលបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការរៀបចំបែបនេះ ធ្វើឡើងដើម្បីឆ្លើយតបទៅនឹងមាត្រា៥៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលចែងថាការយកពន្ធនឹងអាចធ្វើទៅបានលុះ ត្រាតែមានច្បាប់អនុញ្ញាត។

យោងតាមការប៉ាន់ស្មានថ្មីៗបំផុត ពីមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ពន្ធ និងការអភិវឌ្ឍន៍ប្រាក់ចំណូលពន្ធសរុបមានចំនួនច្រើនជាង៨០% នៃប្រាក់ចំណូលសរុបរបស់រដ្ឋាភិបាលប្រហែលពាក់កណ្តាលនៃប្រទេសនានានៅលើពិភពលោក និងច្រើនជាង៥០% នៅស្ទើរតែគ្រប់ប្រទេស។ យើងចាប់ផ្តើមផ្លាស់ប្តូរប្រវត្តិសាស្ត្រនៅទិដ្ឋភាពទូទៅនៃគំរូពន្ធបន្ទាប់មកធ្វើ ការវិភាគទិន្នន័យដែរមានពីរបីទសវត្សចុងក្រោយនេះ ដោយពិភាក្សាអំពីនិន្នាការ និងលំនាំថ្មីៗនៅក្នុងការយកពន្ធជុំវិញពិភពលោក[7]។

### ២.២.៣ ទ្រឹស្តីនៃពន្ធ

ពន្ធ គឺជាបំណុលរបស់បុគ្គលនិវាសនជន ចំពោះចំណូលប្រភពកម្ពុជា និងប្រាក់ចំណូលប្រភពក្រៅកម្ពុជារបស់បុគ្គលអនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា។

- ធ្វើនៅព្រះរាជាណាចក្រកម្ពុជា
- ធ្វើឡើងលើបុគ្គលអនិវាសនជនចំពោះប្រាក់ចំណេញប្រភពកម្ពុជា និងធ្វើឡើងដោយបុគ្គលនិវាសនជន

[7] Facebook Page. រតនាភិរុណ. (2024, February 18). *ពិភពគណនេយ្យ.* Retrieved from https://www.facebook.com/100032074736268/posts .

## ២.៣ ការប្រមូលពន្ធលើប្រាក់ចំណូលផ្តល់សារៈសំខាន់ដល់សេដ្ឋកិច្ចជាតិ

### ២.៣.១ និយមន័យសេដ្ឋកិច្ចជាតិ

-សេដ្ឋកិច្ចជាតិ៖ ជាប្រព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសមួយ ដែលរួមបញ្ចូលនូវអង្គភាពសេដ្ឋកិច្ចទាំងអស់ក្នុងប្រទេសនោះ ដូចជាគ្រួសារ សហគ្រាស រដ្ឋាភិបាល និងវិស័យក្រៅប្រព័ន្ធ។ វាកំណត់ពីរបៀបដែលធនធានត្រូវបានផលិត ចែកចាយ និងប្រើប្រាស់ ដើម្បីបំពេញតម្រូវការរបស់ប្រជាជនក្នុងប្រទេសនោះ។

- សេដ្ឋកិច្ចជាតិ៖ គឺជាការសម្របសម្រួលនៃសកម្មភាពសេដ្ឋកិច្ចទាំងមូលក្នុងប្រទេសនីមួយៗ ដើម្បីរីកចម្រើននិងរឹងមាំផ្នែកសេដ្ឋកិច្ច។

- សេដ្ឋកិច្ចជាតិ៖ គឺជាសំណុំនៃទំនាក់ទំនងសំដៅទៅលើប្រទេសមួយជាពិសេសគិតទៅដល់ប្រជាជនជាធំ ដែលកំពុងស្ថិតក្នុងផលិតកម្ម ការប្រើប្រាស់ និង មានការបែងចែងធនធានកម្រទាំងឡាយក្នុងសង្គមនៅក្នុងទីតាំងមួយមានរដ្ឋាភិបាល ភាសា ទំនៀមទម្លាប់ ប្រពៃណីប្រវត្តិសាស្ត្ររបស់ខ្លួន។

- សេដ្ឋកិច្ចជាតិ៖ ជាប្រព័ន្ធសេដ្ឋកិច្ចទាំងមូលរបស់ប្រទេសមួយ ដែលរួមមានសកម្មភាពនៃការផលិត ការចំណាយ ការនាំចេញនាំចូល ការងារ ការវិនិយោគ និងសេវាផ្សេងៗទៀត[8]។

### ២.៣.២ ប្រវត្តិនៃសេដ្ឋកិច្ចជាតិ

ប្រវត្តិនៃសេដ្ឋកិច្ចជាតិ (National Economic History) គឺជាការសិក្សាអំពីការអភិវឌ្ឍន៍នៃប្រព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសណាមួយតាមកាលៈទេសៈ។ ក្នុងករណីនៃប្រទេសកម្ពុជា ប្រវត្តិសេដ្ឋកិច្ចជាតិស្ថិតនៅក្រោមឥទ្ធិពលនយោបាយ ប្រវត្តិសាស្ត្រ និងបច្ចេកវិទ្យាផ្សេងៗ ដែលអាចបែងចែកបានជាពីរបីដំណាក់កាលសំខាន់ៗ ដូចជា សេដ្ឋកិច្ចសម័យអង្គរ (ប្រហែលសតវត្សទី៩-១៥)ពិភពអង្គរមានសេដ្ឋកិច្ចជាដើម ដោយកសិកម្មជាពិសេសការដាំស្រូវ។ ប្រើប្រាស់ប្រព័ន្ធជលផលដ៏សម្បូរបែប ដូចជាបឹងទន្លេសាប និងខ្សែទឹកស្ទឹង។ការជួញដូរ និងប្រព័ន្ធសេដ្ឋកិច្ចត្រូវបានគ្រប់គ្រងដោយព្រះមហាក្សត្រ និងស្តេច។ សេដ្ឋកិច្ចនៅសម័យអាណានិគមបារាំង (១៨៦៣-១៩៥៣) បារាំងបានគ្រប់គ្រងធនធានធម្មជាតិ និងសេដ្ឋកិច្ច ដោយផ្អែកលើការផលិតអង្ករ កៅស៊ូ និងការនាំចេញធនធាន។ សេដ្ឋកិច្ចកម្ពុជាត្រូវបានរីកចម្រើនតិចតួចក្នុងរចនាសម្ព័ន្ធប្រទេសកសិកម្ម។រីឯសេដ្ឋកិច្ចសម័យឯករាជ្យ(១៩៥៣-១៩៧០) ក្រោយពីទទួលបានឯករាជ្យពីបារាំងវិញ សេដ្ឋកិច្ចត្រូវបានជំរុញដោយរដ្ឋាភិបាលសម័យ ព្រះបាទ នរោត្តសីហនុ ។មានការអភិវឌ្ឍវិស័យសង្គម បច្ចេកវិទ្យា និងអប់រំ។ សេដ្ឋកិច្ចសម័យខ្មែរក្រហម(១៩៧៥-១៩៧៩) មានផលប៉ះពាល់យ៉ាងខ្លាំងខ្មែរ ក្រហមបានបំផ្លាញប្រព័ន្ធសេដ្ឋកិច្ចទាំងមូល ដោយលុបបំបាត់ប្រាក់ និងទីផ្សារ។ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការនៅសហគមន៍ និងស្រែសំណាង់ ដោយគ្មានជំរើសផ្ទាល់ខ្លួន។គោលនយោបាយសេដ្ឋកិច្ចស្មើគ្នា ខ្មែរក្រហមបានប្រកាសលុបចោល សេដ្ឋកិច្ចទីផ្សារ និងសេដ្ឋកិច្ចឯកជន។ ទ្រព្យសម្បត្តិទាំងអស់ ត្រូវបានជ្រើសយកជាសម្ភារៈរដ្ឋ។មិនមានអាជីវកម្មឯកជន ការជួញដូរ ឬក្រុមហ៊ុនឡើយ។ ប្រជាជនមិនអាចកាន់កាប់ដី ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនបានទេ។ លុបចោលប្រាក់ និងប្រព័ន្ធហិរញ្ញវត្ថុនៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបិទធនាគារ និងលុបប្រាក់ចេញពីប្រព័ន្ធ (មិនមានលុយប្រើឡើយ) ពលរដ្ឋមិនអាចទិញឬលក់អ្វីបានទេ ហើយមិនមានប្រាក់ខែទេ គ្រឿងប្រើប្រាស់ត្រូវចែកចាយតាមកំណត់រដ្ឋ។ មិនមានប្រព័ន្ធពន្ធខ្មែរក្រហមបានលុបចោលការបង់ពន្ធទាំងអស់។ ព្រោះគ្មានអាជីវកម្ម ឬអត្រាប្រាក់ចំណូលបុគ្គល ឬក្រុមហ៊ុនទេ ហើយរដ្ឋគ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់។ ការប្រមូលប្រាក់ចំណូលរដ្ឋ តាម

[8] KHsearch. Khem Sarith. (2019, May 19). *អ្វីទៅជាសេដ្ឋកិច្ច?* Retrieved from https://www.khsearch.com/qna/19300

រយៈពន្ធ ត្រូវបានជំនួសដោយការបង្ខំឱ្យប្រជាជនធ្វើការក្នុងសហគមន៍ ដោយគ្មានប្រាក់ឈ្នួល។ ប្រជាជនត្រូវបានរើចេញពីទីក្រុងទៅរស់នៅជាក្រុមសហគមន៍ជនបទ។ សកម្មភាពសេដ្ឋកិច្ចសំខាន់គឺកសិកម្ម និងសំណង់។ ដំណាំ ផលិតផល និងទ្រព្យសម្បត្តិទាំងអស់ ត្រូវជាសម្បត្តិរួម និងបែងចែកដោយរដ្ឋ។ វិបត្តិសេដ្ឋកិច្ច និងផលវិបាក ពុំមានផលិតកម្មល្អ ឬការចែកចាយប្រសើរទេ។ មានការខ្វះអាហារ និងគ្រឿងឧបភោគជាច្រើន។ អ្នកស្លាប់ដោយសារ ស្រាំងបេះដូង ខ្វះអាហារការ រងទណ្ឌកម្ម។ សេដ្ឋកិច្ចរងការប៉ះពាល់ធ្ងន់ធ្ងរ ហើយបន្ទាប់ពីឆ្នាំ ១៩៧៩ ប្រទេសត្រូវចាប់ផ្តើមសង្គ្រោះសេដ្ឋកិច្ចពីដំបូងវិញ។ សេដ្ឋកិច្ចសម័យក្រោយសង្គ្រាម និងស្តារឡើងវិញ (១៩៨០ បច្ចុប្បន្ន)សេដ្ឋកិច្ចបែបរាជានិយម និងគ្រប់គ្រងដោយរដ្ឋ រហូតដល់ការបើកទីផ្សារជាសេរីកាលពីឆ្នាំ ១៩៨៩ (នយោបាយ New Economic Mechanism)។ពីឆ្នាំ ១៩៩៣ មកកម្ពុជាបានបន្តបើកសេដ្ឋកិច្ចទទួលទុនបរទេសនិងការអភិវឌ្ឍយ៉ាងឆាប់រហ័សក្នុង វិស័យទេសចរណ៍ កសិកម្ម និងឧស្សាហកម្ម។ការចាប់ផ្តើមសេដ្ឋកិច្ចទីផ្សារ (Market Economy)បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ និងការកើតឡើងវិញនៃរដ្ឋាភិបាលប្រជាធិបតេយ្យ ប្រទេសបានប្តូរទៅប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។បើកចំហសេដ្ឋកិច្ចដល់វិនិយោគិនបរទេស និងឯកជនក្នុងស្រុក។អាជីវកម្មឯកជន ត្រូវបានអនុញ្ញាត និងលើកទឹកចិត្ត។ការកំណត់ច្បាប់ពន្ធស្តង់ដារជាតិនៅឆ្នាំ ១៩៩៧ នៅឆ្នាំ១៩៩៧ កម្ពុជាបានអនុម័តច្បាប់ស្តីពីសារពើពន្ធ (Law on Taxation) ដែលជាគ្រឹះសំខាន់សម្រាប់ការប្រមូលប្រាក់ចំណូលរដ្ឋ។ បង្កើតអង្គភាពគ្រប់គ្រងពន្ធបង្កើតអគ្គនាយកដ្ឋានពន្ធដារ (GDT) ដើម្បីគ្រប់គ្រងពន្ធក្នុងស្រុក។បង្កើត អគ្គនាយកដ្ឋានគយ និងរដ្ឋាករសេដ្ឋកិច្ច (GDCE) សម្រាប់ការគ្រប់គ្រងពន្ធនាំចូលនាំចេញ។ ប្រើប្រព័ន្ធឌីជីថលដើម្បីប្រមូលពន្ធ (E-filing, E-taxpayer)ការគាំទ្រពីអង្គការអន្តរជាតិអង្គការ IMF, World Bank និង ADB បានផ្តល់ជំនួយ បច្ចេកទេស និងសេវាផែនការកែលម្អប្រព័ន្ធពន្ធ។កម្ពុជាបានចូលរួមជាសមាជិក WTO (២០០៤) និង ASEAN Economic Community (AEC) ដែលជំរុញឲ្យ ប្រព័ន្ធពន្ធស្របតាមស្តង់ដារអន្តរជាតិ។ប្រយោជន៍នៃប្រព័ន្ធពន្ធថ្មីដែលបង្កើតប្រាក់ចំណូលជូនរដ្ឋប្រើសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសេវាសាធារណៈ (សាលារៀន មន្ទីរពេទ្យ ផ្លូវលំ...)[9]។

**២.៣.៣ ទ្រឹស្តីសេដ្ឋកិច្ចជាតិ**

ទ្រឹស្តីសេដ្ឋកិច្ចជាតិ (National Economic Theory) គឺជាសំណុំគំនិត ឬគោលការណ៍ដែលពិចារណាអំពីវិធីសាស្ត្រ និងយុទ្ធសាស្ត្រសេដ្ឋកិច្ចរបស់ប្រទេសមួយ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិ ធានាការលូតលាស់ និងស្ថិរភាពសេដ្ឋកិច្ច។ ទ្រឹស្តីសេដ្ឋកិច្ចជាតិអាចរួមមានចំណុចសំខាន់ៗដូចជា៖

1. អត្ថប្រយោជន៍ជាតិ (National Interest): ផ្តោតលើការបង្កើនផលចំណេញសុវត្ថិភាព និងសេរីភាពសេដ្ឋកិច្ចរបស់ប្រទេសខ្លួន។

2. ការការពារផលិតកម្មក្នុងស្រុក (Protectionism): ជាបច្ចេកទេសសេដ្ឋកិច្ចដើម្បីការពារឧស្សាហកម្មក្នុងស្រុកតាមរយៈពន្ធនាំចូល ឬគ្រប់គ្រងទីផ្សារនាំចូល។

3.ការរីកចម្រើនសេដ្ឋកិច្ច ផ្តោតលើការលើកកម្ពស់ផលិតកម្ម បង្កើនការងារ និងធនធានជាតិ។

4. គោលនយោបាយរដ្ឋ៖រដ្ឋមានគោលនយោបាយសំខាន់ៗនៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ច ដូចជាតម្លៃប្រាក់ការវិនិយោគសាធារណៈ និងការគ្រប់គ្រងថវិកាជាតិ។

---

[9] សន ស៊ីថន. (2010, October 19). *ចំណាត់ ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា(ច.ស.វ.ក).* https://nis.gov.kh/nis/CSIC/CSIC_V1_KH (27.08.2025)

5. ទំនាក់ទំនងអន្តរជាតិ៖ ការជ្រៀតជ្រែកពាណិជ្ជកម្ម និងការទាក់ទងសេដ្ឋកិច្ចជាមួយប្រទេសផ្សេងៗ ក៏ជាផ្នែកមួយនៃទ្រឹស្តីសេដ្ឋកិច្ចជាតិ។
6. សេដ្ឋកិច្ចទីផ្សារសេរីជាមួយនឹងការគ្រប់គ្រងពីរដ្ឋបាលកម្ពុជាបានធ្វើការផ្លាស់ប្តូរ ពីសេដ្ឋកិច្ចផែនការចាស់មកជាសេដ្ឋកិច្ចទីផ្សារសេរីចាប់ពីឆ្នាំ១៩៨៩ តទៅ។

   តែរដ្ឋនៅតែមានក្នុងការគ្រប់គ្រងផ្នែកសំខាន់ៗ ដូចជា៖

   - គ្រប់គ្រងលើគម្រោងវិនិយោគធំៗ
   - បង្កើនសេវាសាធារណៈ
   - ជម្រុញវិស័យឯកជន
   - អភិវឌ្ឍ វិស័យកសិកម្ម និងវិស័យឧស្សាហកម្ម
7. គោលនយោបាយត្រីកោណអភិវឌ្ឍន៍

   ជាសំណុំយុទ្ធសាស្ត្រសំខាន់របស់រដ្ឋាភិបាល ដែលផ្តោតលើ៖

   - ការរីកចម្រើនសេដ្ឋកិច្ច
   - ការអភិវឌ្ឍធនធានមនុស្ស
   - ស្ថិរភាពនយោបាយ និងសន្តិសុខ
   - ការកែប្រែនីតិបញ្ញត្តិ និងគ្រប់គ្រងល្អ
8. យុទ្ធសាស្ត្រអភិវឌ្ឍជាតិ

   ជាគម្រោងរយៈពេលមធ្យមនិងវែងដើម្បី៖

   - បង្កើនផលិតភាពក្នុងវិស័យកសិកម្ម
   - ជម្រុញឧស្សាហកម្ម និងសេវាកម្ម
   - ទាក់ទាញវិនិយោគបរទេស
   - កាត់បន្ថយភាពក្រីក្រ
9. គោលដៅរួមនៃកម្ពុជា
   - ការពង្រឹងសេដ្ឋកិច្ចឱ្យមានស្ថិរភាព និងការរីកចម្រើនចីរភាព
   - ការលើកកម្ពស់ជីវភាពប្រជាជន
   - ការអភិវឌ្ឍជាតិទាំងមូលតាមគន្លងឌីជីថល និងបច្ចេកវិទ្យា[10]។

[10] Facebook page. វេនាភិរុណ. (2024 feb18). *ពិភពគណនេយ្យ*. Retrieved from https://www.facebook.com/100032074736268/posts

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ



> ១៩៥៣៖ ត្រូវបានបង្កើតឡើងជានាយកដ្ឋានពន្ធដារ

> ១៩៧៥-១៩៧៩៖ ពន្ធដារត្រូវលុបបំបាត់ចោលដោយរបបប៉ុលពត

> ១៩៨០៖ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ

> ២០០៨៖ នាយកដ្ឋានពន្ធដារបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារកម្ពុជាត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៤ តាមរយៈការប្រព្រឹត្តិនូវច្បាប់ និងគោលការណ៍ដែលទាក់ទងនឹងការប្រមូលប្រាក់ពន្ធនៅក្នុងប្រទេស។ ហើយវាបានផ្តល់ឲ្យមានអំណាច និងកម្លាំងនៅក្នុងការប្រមូលប្រាក់ពន្ធសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការទទួលខុសត្រូវចំពោះការអនុវត្តនឹងការផ្តល់ពន្ធត្រឹមត្រូវ។ពន្ធដារចាប់ផ្តើមបង្កើតឡើង ដើម្បីទទួលបានប្រាក់ពន្ធនៅក្នុងប្រទេសដោយប្រើវិធីសាស្រ្ត និងប្រព័ន្ធទំនាក់ទំនងថ្មីៗ ពីព្រោះការផ្លាស់ប្តូរនៅក្នុងសេដ្ឋកិច្ចជាតិ និងប្រព័ន្ធរដ្ឋាភិបាលរបស់អគ្គនាយកដ្ឋានពន្ធដារបានជួយឲ្យការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាកាន់តែមានស្ថិរភាព នឹងប្រសើរឡើងនៅក្នុងការអនុវត្តន៍យ៉ាងត្រឹមត្រូវនៃការប្រមូលប្រាក់ពន្ធ។ ក៏ប៉ុន្តែរាជរដ្ឋាភិបាលត្រូវបានផ្តល់អំណាចក្នុងការអនុវត្តគោលការណ៍របស់ពន្ធដារ ដើម្បីគ្រប់គ្រងការប្រមូលប្រាក់ពន្ធពីប្រជាជននិងអាជីវកម្មផ្សេងៗ។ នាយកដ្ឋានពន្ធដារ (General Department of Taxation) នៅកម្ពុជា ជាស្ថាប័នមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិង

ហិរញ្ញវត្ថុ។ ការអនុវត្តន៍និងគ្រប់គ្រងក្នុងការបើកប្រាក់ពន្ធប្រតិបត្តិការនានា ដើម្បីធានាថាការបង់ពន្ធនៅប្រទេសកម្ពុជាអាចប្រកបដោយប្រសិទ្ធភាព និងមានអត្ថប្រយោជន៍ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

អគ្គនាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦១ ដោយមានគោលបំណងធ្វើការគ្រប់គ្រងការបង់ពន្ធ និងត្រួតពិនិត្យនូវការអនុវត្តតាមច្បាប់ពន្ធក្នុងប្រទេសកម្ពុជា។ ការចាត់តាំងបុគ្គលិកនៅក្នុងអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានកំណត់ជាចម្បងដើម្បីពង្រឹងការប្រមូលពន្ធ និងធានានូវការគ្រប់គ្រងអំពើការប្រមូលពន្ធតាមច្បាប់យ៉ាងតឹងរ៉ឹង។ អគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិ និងភារកិច្ចក្នុងការបញ្ចេញវិធានការ និងច្បាប់នានាក្នុងការប្រមូលពន្ធដារនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងអំឡុងពេលបច្ចុប្បន្នសំណង់វិស័យអគ្គនាយកដ្ឋានពន្ធដារ កំពុងតែធ្វើការកែលម្អនូវប្រព័ន្ធពន្ធដារដើម្បីបង្កើនការចុះបញ្ជីពន្ធ និងជំរុញការកែប្រែបែបបទនៅក្នុងប្រព័ន្ធពន្ធដារ ដែលនឹងធានាបាននូវប្រសិទ្ធភាព ល្អបំផុតក្នុងការប្រមូលពន្ធ។ ហើយបច្ចុប្បន្ននេះដែរ នាយកដ្ឋានពន្ធដារ គឺជារដ្ឋាភិបាលមួយយ៉ាងសំខាន់នៅក្នុងការប្រមូលប្រាក់ពន្ធ និងគ្រប់គ្រងប្រព័ន្ធពន្ធនៃប្រទេសកម្ពុជា។ អគ្គនាយកដ្ឋានពន្ធដារត្រូវបានគ្រប់គ្រងដោយមន្ត្រីជាន់ខ្ពស់ និងមានការលើកកម្ពស់បច្ចេកវិទ្យា និងប្រព័ន្ធទំនាក់ទំនងថ្មីៗ ដូចជាប្រព័ន្ធបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ និងការពិនិត្យដោយផ្ទាល់ និងស្វែងយល់ទិន្នន័យពន្ធ ដើម្បីធានាបានថាផលិតភាពនៃការប្រមូលប្រាក់ពន្ធឱ្យកាន់មានប្រសិទ្ធភាពកាន់តែខ្លាំងឡើង។ រដ្ឋាភិបាលបានធ្វើការផ្លាស់ប្តូរក្នុងការអភិវឌ្ឍន៍ប្រព័ន្ធពន្ធដារ ដោយជំរុញការប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការសម្រួលសេវាកម្មដល់ប្រជាពលរដ្ឋ និងអាជីវកម្មក្នុងការបង់ពន្ធជូនរដ្ឋ។ ដូច្នេះហើយ នៅក្នុងបច្ចុប្បន្ននេះវិស័យពន្ធដារ កំពុងធ្វើការកែលម្អនូវប្រព័ន្ធពន្ធដារដើម្បីបង្កើនការចុះបញ្ជីពន្ធ និងជំរុញការកែប្រែបែបបទនៅក្នុងប្រព័ន្ធពន្ធដារ ដែលនឹងធានាបាននូវប្រសិទ្ធភាពឱ្យកាន់តែល្អបំផុតក្នុងការប្រមូលពន្ធ។

នៅក្នុងឆ្នាំ២០២៣ អគ្គនាយកដ្ឋានពន្ធដារ បានប្រមូលចំណូលពន្ធបាន១៣,៩៣៣,៥៣០ លានរៀល (ប្រហែល ៣,៤៣៨លានដុល្លារ) ដែលលើសពីផែនការដែលបានកំណត់។ ការប្រឡងនេះបានធ្វើឡើងនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៥ ដើម្បីជ្រើសរើសមន្ត្រីជំនាញចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារហើយក៏បានធ្វើ ផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ ដើម្បីបន្តការកែទម្រង់ និងពង្រឹងប្រព័ន្ធពន្ធដារ។ ផែនការនេះបានបង្ហាញពីទិសដៅនៃការអភិវឌ្ឍន៍ប្រព័ន្ធពន្ធដារនិងការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ ។

### *សញ្ញសម្គាល់

ខាងក្រោមនេះ គឺជាសញ្ញាសម្គាល់ផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ។

រូបភាពទី១: សញ្ញសម្គាល់

### ៣.១.២ បេសកម្ម ទស្សនវិស័យ និងគោលដៅរបស់ពន្ធដារ

### ✧ បេសកម្ម

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មធ្វើឱ្យសម្រេចការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមការៈ

•ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមានៈ ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ

•ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូល ថវិកាជាតិ

•បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព

•បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយកិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន

✧ ទស្សនវិស័យ

អគ្គនាយកដ្ឋានពន្ធដារ មានទស្សនវិស័យជាស្ថាប័នសាធារណៈ ដែលត្រូវបានជឿជាក់គោរព និងទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធ ក្នុងស្រុកដើម្បីចូលរួមអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយចីរភាព។

✧ គោលដៅរបស់ពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ មានគោលដៅសំខាន់ៗជាច្រើនក្នុងការចាត់ការពន្ធ ដើម្បីធានាថាប្រព័ន្ធពន្ធដារនៅកម្ពុជាបានអភិវឌ្ឍ និងមានប្រសិទ្ធភាព។ ខាងក្រោមជាគោលដៅសំខាន់ៗ៖

- បង្កើនចំណូលរដ្ឋ ដើម្បីប្រើសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និងបម្រើប្រជាពលរដ្ឋ(អភិវឌ្ឍន៍ផ្លូវថ្នល់ ផ្តល់សេវាសុខាភិបាល ការអប់រំ និងសេវាធម្មការ)។

- ពង្រឹងប្រព័ន្ធពន្ធដារ បង្កើនឱ្យមានប្រសិទ្ធភាព និងភាពស្របច្បាប់ក្នុងការប្រមូលពន្ធ។

- ជំរុញការស្វែងរកប្រាក់ចំណូលដោយស្របច្បាប់ ដើម្បីជៀសវាងការបោកបន្លំ និងការចៀសពន្ធ។

- ជំរុញសេដ្ឋកិច្ចឱ្យមានការរីកចម្រើនការវិនិយោគ និងការបង្កើតការងារ។

- បង្កើនភាពស្មើភាពសេដ្ឋកិច្ច និងសង្គមធានាថាមនុស្សដែលមានចំណូលខ្ពស់បង់ពន្ធខ្ពស់ជាងអ្នកដែលមានចំណូលទាប។

- បង្ការ និងកាត់បន្ថយអំពើពុករលួយក្នុងប្រព័ន្ធពន្ធដារធ្វើឱ្យប្រព័ន្ធពន្ធដារមានភាពត្រឹមត្រូវ និងតម្លាភាព ដើម្បីជៀសវាងការប្រើអំណាចក្នុងការចៀសពន្ធ។

- ធានាការបង់ពន្ធត្រឹមត្រូវដោយផ្តល់ការសិក្សាអប់រំអំពីកាតព្វកិច្ចបង់ពន្ធដល់ប្រជាពលរដ្ឋ និងអាជីវកម្មដើម្បីធានាថា អ្នកបង់ពន្ធអនុវត្តតាមច្បាប់។

សរុបជារួមមកគោលដៅរបស់ពន្ធជា គឺជាការបង្កើនប្រសិទ្ធភាពក្នុងការប្រមូលពន្ធ ដើម្បីពង្រឹងសេដ្ឋកិច្ច និងបម្រើសង្គម។ វាមិនត្រឹមតែជាវិធីសាស្ត្រសម្រាប់ប្រមូលចំណូលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាឧបករណ៍មួយដ៏សំខាន់សម្រាប់ការជំរុញការវិនិយោគ ការបង្កើតការងារ និងការបង្កើនសុភមង្គលរបស់ប្រជាពលរដ្ឋ។

### ៣.១.៣ រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ




+អគ្គនាយកដ្ឋានពន្ធដារៈអាជ្ញាធរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យនិងតាមដានការអនុវត្តច្បាប់លើ រួមមានៈ

- អជ្ញាធរសវនមកម្មជាតិ
- អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គធិការដ្ឋាន នៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អង្គភាពប្រឆាំងអំពើរពុករលួយ

+សាខាពន្ធដារខណ្ឌៈ មានសាខាចំនួន៩

+សាខាពន្ធដារខេត្តៈ មានសាខាចំនួន២៤

## ៣.២ ដំណើរការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.២.១ ការចុះបញ្ជីជាអ្នកជាប់ពន្ធ

បុគ្គល ឬសហគ្រាសដែលមានប្រាក់ចំណូលត្រូវតែចុះឈ្មោះជាផ្លូវការជាមួយអគ្គនាយកដ្ឋានពន្ធដារ ដើម្បីទទួលបានលេខអត្តសញ្ញាណអ្នកបង់ពន្ធ(TIN) ដែលមានសារៈសំខាន់ក្នុងការតាមដាន និងគ្រប់គ្រងការបង់ពន្ធរបស់ពួកគេ។

➢ មាន៤ប្រការដូចខាងក្រោម

១-បុគ្គលទាំងឡាយ ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥ថ្ងៃ នៃថ្ងៃធ្វើការក្រោយពីបុគ្គល នោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ។ បុគ្គលដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារ ជាអាទិ៍មានៈ

ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ។

ខ. ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត សាខាក្រុមហ៊ុន បរទេស ការិយាល័យតំណាង សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហគ្រាសសាធារណៈ សហគ្រាសរដ្ឋ និងក្រុមហ៊ុនចម្រុះរដ្ឋ។

គ. សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

ឃ. បុគ្គលដទៃទៀតដែលធ្វើសកម្មភាពអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។

➢ពន្ធលើប្រាក់ចំណូលជាប្រភេទពន្ធសំខាន់មួយ ដែលអគ្គនាយកដ្ឋានពន្ធដារ(GDT) នៅកម្ពុជាប្រើប្រាស់សម្រាប់ប្រមូលប្រាក់ចំណូលរដ្ឋ ដើម្បីគាំទ្រចំណាយសាធារណៈ និងការអភិវឌ្ឍប្រទេស។ ដំណើរការប្រមូលពន្ធនេះត្រូវបានដំណើរការយ៉ាងមានប្រព័ន្ធ ដើម្បីធានាបាននូវភាពស្របច្បាប់ មានប្រសិទ្ធភាព និងមានតម្លាភាព។

ខាងក្រោមជាចំណុចសំខាន់ៗនៃដំណើរការប្រមូលពន្ធលើប្រាក់ចំណូល៖

**១.អ្នកជាប់ពន្ធតូច៖**

លក្ខខណ្ឌកំណត់ជាមួយអ្នកជាប់ពន្ធតូចចំណាត់ថ្នាក់អ្នកជាប់ពន្ធ ត្រូវបានកំណត់តាម២ករណីដោយឡែកពីគ្នាចំពោះសហគ្រាសដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ក.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**

ការកំណត់ចំណាត់ថ្នាក់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំ ទៅតាមវិស័យចម្បងរួមមានវិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងពាណិជ្ជកម្ម។ សហគ្រាសដែលត្រូវបានចាត់ចូលជាអ្នកជាប់ពន្ធតូច ប្រសិនបើស្ថិតក្នុងចំណោមលក្ខខណ្ឌកំណត់ណាមួយដូចខាងក្រោម៖

- មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀល ដល់ ១ ០០០លានរៀល សម្រាប់វិស័យកសិកម្ម, សេវាកម្ម និងពាណិជ្ជកម្ម
- មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ១ ៦០០លានរៀល សម្រាប់វិស័យឧស្សាហកម្ម
- មានផលរបរក្នុងរយៈពេល៣ខែ ជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី ៦០លានរៀលឡើងទៅ
- រំពឹងថា មានផលរបរក្នុងរយៈពេល៣ខែ ជាប់គ្នាខាងមុខ ចាប់ពី៦០លានរៀលឡើងទៅ
- ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នង់ថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញឬសេវារួមទាំងភាសុី

**ខ.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្មអាជីវកម្ម**

ក្នុងករណីផលរបរ ដែលអ្នកជាប់ពន្ធបានប្រកាសមិនឆ្លុះបញ្ចាំងនូវផលរបរជាក់ស្តែង ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធត្រូវបានធ្វើឡើងវិញ ដោយផ្អែកលើតម្លៃទ្រព្យសកម្មដែលប្រើប្រាស់ក្នុងអាជីវកម្ម។ សហគ្រាស ដែលត្រូវបានចាត់ចូលជាអ្នកជាប់ពន្ធតូច ប្រសិនបើស្ថិតក្នុងចំណោមលក្ខខណ្ឌកំណត់ណាមួយ ដូចខាងក្រោម៖

- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំ២០០ លានរៀល ដល់ ១ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម
- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំ២០០ លានរៀលដល់ ២ ០០០ លានរៀលសម្រាប់វិស័យឧស្សាហកម្ម។

**២ អ្នកជាប់ពន្ធមធ្យម៖**

លក្ខខណ្ឌកំណត់ ជាអ្នកជាប់ពន្ធមធ្យមចំណាត់ថ្នាក់អ្នកជាប់ពន្ធ ត្រូវបានកំណត់តាម២ករណីដោយឡែកពីគ្នា ចំពោះសហគ្រាសដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ក.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**

ការកំណត់ចំណាត់ថ្នាក់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំ ទៅតាមវិស័យចម្បងរួមមាន វិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងពាណិជ្ជកម្ម។ សហគ្រាសដែលត្រូវបានចាត់ចូលជាអ្នកជាប់ពន្ធមធ្យមប្រសិនបើស្ថិតក្នុងចំណោមលក្ខខណ្ឌកំណត់ណាមួយដូចខាងក្រោម៖

- មានផលរបរប្រចាំឆ្នាំលើសពី ១ ០០០ លានរៀល ដល់ ៤ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម
- មានផលរបរប្រចាំឆ្នាំលើសពី ១ ០០០ លានរៀល ដល់ ៦ ០០០ លានរៀល សម្រាប់វិស័យសេវាកម្ម និងពាណិជ្ជកម្ម
- មានផលរបរប្រចាំឆ្នាំលើសពី ១ ៦០០ លានរៀល ដល់ ៨ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម
- ជាសហគ្រាស ដែលបានចុះបញ្ជីជានីតិបុគ្គល ការិយាល័យតំណាង
- ជាស្ថាប័នរដ្ឋថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សមាគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាលនានា ឬគម្រោងដែលស្ថិតក្រោមស្ថាប័នទាំងនេះ
- ជាបេសកកម្មទូត និងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ឬគម្រោងដែលស្ថិតក្រោមស្ថាប័នទាំងនេះ។

**ខ.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្មអាជីវកម្ម**

ក្នុងករណីផលរបរដែលអ្នកជាប់ពន្ធបានប្រកាសមិនឆ្លុះបញ្ចាំងនូវផលរបរជាក់ស្តែង ការកំណត់ ចំ

ណាត់ថ្នាក់អ្នកជាប់ពន្ធត្រូវបានធ្វើឡើងវិញដោយផ្អែកលើតម្លៃទ្រព្យសកម្មដែលប្រើប្រាស់ក្នុងអាជីវកម្ម។ សហគ្រាសដែលត្រូវបានចាត់ចូលជាអ្នកជាប់ពន្ធមធ្យម ប្រសិនបើស្ថិតក្នុងចំណោមលក្ខខណ្ឌកំណត់ណាមួយដូចខាងក្រោម៖

- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំ ១០០០ លានរៀល ដល់ ២ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម
- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំ ២ ០០០ លានរៀលដល់ ៤ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម

**៣ អ្នកជាប់ពន្ធធំ៖**

លក្ខខណ្ឌកំណត់ ជាអ្នកជាប់ពន្ធធំមានចំណាត់ថ្នាក់អ្នកជាប់ពន្ធ ត្រូវបានកំណត់តាម២ករណីដោយឡែកពីគ្នាចំពោះសហគ្រាសដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ក.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស**

ការកំណត់ចំណាត់ថ្នាក់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំទៅតាមវិស័យចម្បងរួមមាន វិស័យកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងពាណិជ្ជកម្ម។ សហគ្រាសដែលត្រូវបានចាត់ចូលជាអ្នកជាប់ពន្ធធំ ប្រសិនបើស្ថិតក្នុងចំណោមលក្ខខណ្ឌកំណត់ណាមួយដូចខាងក្រោម៖

- មានផលរបរប្រចាំឆ្នាំលើសពី ៤ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម
- មានផលរបរប្រចាំឆ្នាំលើសពី ៦ ០០០ លានរៀល សម្រាប់វិស័យសេវាកម្ម និងពាណិជ្ជកម្ម
- មានផលរបរប្រចាំឆ្នាំលើសពី ៨ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម
- ជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស
- ជាសហគ្រាសដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។

**ខ.ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមទ្រព្យសកម្មអាជីវកម្ម**

ក្នុងករណីផលរបរ ដែលអ្នកជាប់ពន្ធបានប្រកាសមិនឆ្លុះបញ្ចាំងនូវផលរបរជាក់ស្តែង ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធត្រូវបានធ្វើឡើងវិញ ដោយផ្អែកលើតម្លៃទ្រព្យសកម្មដែលប្រើប្រាស់ក្នុងអាជីវកម្ម។ សហគ្រាសដែលត្រូវបានចាត់ចូលជាអ្នកជាប់ពន្ធធំ ប្រសិនបើ ស្ថិតក្នុងចំណោមលក្ខខណ្ឌកំណត់ណាមួយដូចខាងក្រោម៖

- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ២ ០០០ លានរៀល សម្រាប់ធ្វើវិស័យកសិកម្មសេវាកម្ម និងពាណិជ្ជកម្ម
- មានទ្រព្យសកម្មអាជីវកម្មប្រចាំឆ្នាំលើសពី ៤ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម។

### ៣.២.២ អត្រាពន្ធលើប្រាក់ចំណូល

#### ប្រការ៤៩. អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំត្រូវបានកំណត់ដូចខាងក្រោម៖

១- អត្រា ២០ (ម្ភៃ) ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយនីតិបុគ្គល។

២- អត្រា ៣០ (សាមសិប) ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា។

៣- អត្រា ០ (សូន្យ) ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធ។

៤- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គលដូចខាងក្រោម៖

| **ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ** (**គិតជារៀល**) | | | **អត្រាពន្ធ** |
|---|---|---|---|
| ពី | 0៛ ដល់ | ១៨ 000 000៛ | 0% |
| ពី | ១៨ 000 00១៛ ដល់ | ២៤ 000 000៛ | ៥% |
| ពី | ២៤ 000 00១៛ ដល់ | ១០២ 000 000៛ | ១0% |
| ពី | ១០២ 000 00១៛ ដល់ | ១៥0 000 000៛ | ១៥% |
| | លើសពី | ១៥0 000 000៛ | ២0% |

#### ប្រការ៥១. ប្រាក់ចំណូលជាប់ពន្ធ

១-ការបញ្ចូលមកវិញនិងការកាត់ចេញចំណូលផ្សេងៗ ៖ អាស្រ័យដោយបទប្បញ្ញត្តិស្តីពីពន្ធដារមិនស្របគ្នាទាំងស្រុងទៅនឹង វិធានគណនេយ្យ នាំឱ្យប្រាក់ចំណូលជាប់ពន្ធអាចមិនស្មើគ្នានឹងប្រាក់ចំណេញគណនេយ្យទេ។ដូច្នេះ ដើម្បីគណនាប្រាក់ ចំណូលជាប់ពន្ធនៃឆ្នាំជាប់ពន្ធណាមួយ សហគ្រាសត្រូវយកលទ្ធផលគណនេយ្យមុនបង់ពន្ធនៃឆ្នាំជាប់ពន្ធនោះ មកធ្វើការ កែតម្រូវដូចខាងក្រោម៖

ក- បូកបញ្ចូលមកវិញនូវចំណាយមិនអនុញ្ញាតឱ្យកាត់កង ដូចជា÷

- ចំណាយរំលស់គណនេយ្យ
- ចំណាយលើការកំសាន្តសប្បាយ ការលំហែកំសាន្តនិងការទទួលភ្ញៀវ
- ការកើនឡើងនូវសំវិធានធន
- អំណោយនិងឧបត្ថម្ភកធនផ្សេងៗ
- ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបញ្ជីគណនេយ្យ

- ចំណាយផ្សេងទៀតដែលមិនអនុញ្ញាតឱ្យកាត់កង

ខ- បូកបញ្ចូលមកវិញ នូវចំណូលជាប់ពន្ធដែលមិនត្រូវបានកត់ត្រាជាចំណូលក្នុងបញ្ជីគណនេយ្យ ដូចជា៖

- ការផ្គត់ផ្គង់ទំនិញនិងសេវាដោយឥតគិតថ្លៃ
- អំណោយនិងឧបត្ថម្ភកធនផ្សេងៗ
- តម្លៃលើសពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់ចំណូល
- ចំណូលជាប់ពន្ធផ្សេងទៀតដែលមិនបានកត់ត្រាក្នុងបញ្ជីគណនេយ្យ

គ- ដកចេញវិញនូវចំណាយមិនកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណាយកាត់កងបានក្នុងឆ្នាំ៖

- រំលស់អនុញ្ញាតតាមច្បាប់ស្តីពីសារពើពន្ធ
- រំលស់ពិសេសអនុញ្ញាតតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់ចំណូល
- ការថយចុះនូវសំវិធានធន
- ខាតពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់ចំណូល
- ចំណាយផ្សេងៗទៀតអនុញ្ញាតឱ្យកាត់កងបាន

ឃ- ដកចេញវិញនូវចំណូលបានកត់ត្រាក្នុងបញ្ជីគណនេយ្យ តែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ៖

- ចំណូលលើភាគលាភទទួលបានពីអ្នកជាប់ពន្ធនិវាសនជន
- ចំណេញពីការលក់ទ្រព្យសកម្មរយៈពេលវែងតាមបញ្ជីគណនេយ្យ
- ចំណូលផ្សេងៗបានកត់ត្រាក្នុងបញ្ជីតែជាចំណូលមិនត្រូវជាប់ពន្ធក្នុងឆ្នាំ

២- ក្រោយពីបានធ្វើការកែតម្រូវដូចមកដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រកានេះ សហគ្រាសត្រូវបានគណនា និងវិភាគទាន សប្បុរសធម៌ ដែលអាចកាត់កងបានតាមបទប្បញ្ញត្តិនៃពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំជាប់ពន្ធដោយត្រូវអនុវត្តដូចខាងក្រោម៖

ក-គណនាមូលដ្ឋានសម្រាប់គិតវិភាគទានសប្បុរសធម៌ ដោយត្រូវយកទៅវិភាគទានសប្បុរសធម៌ដែលបានចំណាយនៅក្នុងឆ្នាំជាប់ពន្ធ ទៅបូកនឹងលទ្ធផលក្រោយការកែតម្រូវដែលបានគណនាតាម កថាខណ្ឌ១ នៃប្រកានេះ

ខ-គណនាវិភាគទានសប្បុរសធម៌អតិបរមាដែលអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ ដោយយកលទ្ធផលដែល បានគណនាក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ ទៅគុណនឹង៥ ភាគរយ

គ- វិភាគទានសប្បុរសធម៌អាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ÷

- ក្នុងករណីទឹកប្រាក់វិភាគទានសប្បុរសធម៌ ក្នុងឆ្នាំជាប់ពន្ធតិចជាង ឬស្មើនឹងវិភាគទានសប្បុរសធម៌អតិបរមាអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ គ្មានការកែតម្រូវចំណាយវិភាគទានសប្បុរសធម៌ទេ
- ក្នុងករណីទឹកប្រាក់ដែលវិភាគទានសប្បុរសធម៌ក្នុងឆ្នាំជាប់ពន្ធ ច្រើនជាងវិភាគទានសប្បុរសធម៌អតិបរមា ដែលអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធទឹកប្រាក់លម្អៀង ត្រូវចាត់ទុកជាចំណាយមិនអាចកាត់កងបានសម្រាប់ឆ្នាំជាប់ពន្ធ។ ទឹកប្រាក់លម្អៀងនេះ ត្រូវបូកបញ្ចូលវិញទៅក្នុង

លទ្ធផលក្រោយការកែតម្រូវ ដែលបានគណនាតាមកថាខណ្ឌ១ នៃប្រការនេះ ដើម្បីរកលទ្ធផលក្រោយការកាត់កងវិភាគទានសប្បុរសធម៌

៣- បន្ទាប់មកសហគ្រាសត្រូវគណនារកលទ្ធផលក្រោយការកែតម្រូវការប្រាក់ដោយៈ

ក-គណនាប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់ ដោយយកលទ្ធផលសរុបក្រោយពីការកាត់កងវិភាគទាននិងសប្បុរសធម៌ ត្រូវទៅបូកបញ្ចូលចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធ រួចដកនិងចំណូលការប្រាក់ក្នុងឆ្នាំជាប់ពន្ធ

ខ- គណនាចំណាយការប្រាក់អតិបរមាអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ដោយយកចំណូលការប្រាក់ក្នុងឆ្នាំជាប់ពន្ធទៅបូកនឹង ៥០ ភាគរយ នៃប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់ដូចបានគណនាក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ

គ- ក្នុងករណីចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធ ច្រើនជាងចំណាយការប្រាក់អតិបរមាដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ សហគ្រាសត្រូវគណនាចំណាយការប្រាក់ដែលមិនអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ ដោយយក ចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធដកចំណាយការប្រាក់អតិបរមា ដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធដែលបានគណនាក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះ។ ចំណាយការប្រាក់ដែលនៅសល់ពីការកាត់កងនេះ ត្រូវបាន ចាត់ទុកជាចំណាយការប្រាក់សម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ រហូតដល់ឆ្នាំជាប់ពន្ធទី៥ តាមលំដាប់ឆ្នាំដែលចំណាយ ការប្រាក់បានកើតឡើងតាមវិធីដូចមានចែងក្នុងកថាខណ្ឌនេះ

ឃ- ក្នុងករណីចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធ ស្មើនឹងចំណាយការប្រាក់អតិបរមាដែលអាចកាត់កងបានក្នុងឆ្នាំ ជាប់ពន្ធ ចំណាយការប្រាក់ត្រូវបានអនុញ្ញាតទាំងស្រុងដោយមិនមានការកែតម្រូវទេ

ង- ក្នុងករណីចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធ មានចំនួនតិចជាងចំណាយការប្រាក់អតិបរមាដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធអាចកាត់កងបានទាំងអស់សម្រាប់ឆ្នាំជាប់ពន្ធ។ប្រសិនបើសហគ្រាសមានចំណាយការប្រាក់ដែលនៅសល់យោងពីឆ្នាំមុនមកសហគ្រាសអាចយកមកកាត់កងបានប៉ុន្តែ ចំនួនដែលត្រូវបានអនុញ្ញាតឱ្យកាត់កងសរុប មិនត្រូវឱ្យលើសពីចំណាយការប្រាក់អតិបរមាដែលអាចកាត់ កងបានក្នុងឆ្នាំជាប់ពន្ធទេ។ ក្នុងករណីនេះ ការប្រាក់យោងពីឆ្នាំមុនដែលអនុញ្ញាតឱ្យកាត់កងត្រូវដកចេញពី ចំណូលជាប់ពន្ធ

ច- ការគណនាលទ្ធផលក្រោយការកែតម្រូវការប្រាក់ពន្ធក្នុងឆ្នាំជាប់ពន្ធ ដោយយកលទ្ធផលក្រោយការកាត់កងវិភាគទាន សប្បុរសធម៌ បូកចំណាយការប្រាក់ដែលមិនអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធ តាមវាក្យខណ្ឌ គ ឬដកចំណាយ ការប្រាក់យោងពីឆ្នាំមុន តាមវាក្យខណ្ឌ ង។

៤- គណនាប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ដោយយកលទ្ធផលក្រោយការកែតម្រូវការប្រាក់ក្នុងឆ្នាំជាប់ពន្ធ តាមវាក្យខណ្ឌ ច នៃកថាខណ្ឌ៣ នៃប្រការនេះ ដកការខាតបង់ពីឆ្នាំមុនៗដែលបានអនុញ្ញាតតាមច្បាប់ស្តីពីសារពើពន្ធ ប្រសិនបើមាន។

**ប្រការ៥២. ការគណនាពន្ធលើប្រាក់ចំណូល**

ពន្ធលើប្រាក់ចំណូល ត្រូវបានគណនាដូចតទៅ៖

ក- ការគណនាពន្ធលើប្រាក់ចំណូលដោយយកប្រាក់ចំណូលជាប់ពន្ធនៃឆ្នាំជាប់ពន្ធ ដូចបានគណនាក្នុងប្រការ៥១ នៃប្រកាសនេះ ទៅគុណនឹងអត្រាពន្ធដូចមានចែងក្នុងមាត្រា២០ ថ្មី (មួយ) នៃច្បាប់ស្ដីពីសារពើពន្ធ

ខ- ដកឥណទានពន្ធបរទេសតាមមាត្រា ៣៦ នៃច្បាប់ស្ដីពីសារពើពន្ធ ដូចមានចែងក្នុងប្រការ៥៧ នៃប្រកាស នេះ ចំពោះសហគ្រាសនិវាសនជនដែលមានប្រាក់ចំណូលប្រភពបរទេស ប៉ុន្តែមិនត្រូវឱ្យលើសពីពន្ធលើ ប្រាក់ចំណូលក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌនេះទេ

គ- ដកប្រាក់ពន្ធបង់មុនលើការបែងចែកភាគលាភ ដែលបានបង់ដោយសហគ្រាសតាមមាត្រា២៣ ថ្មី (ពីរ) នៃច្បាប់ស្ដីពីសារពើពន្ធ ប៉ុន្តែមិនត្រូវឱ្យលើសពីពន្ធលើប្រាក់ចំណូលបន្ទាប់ពីកាត់កងឥណទានពន្ធបរទេសក្នុង វាក្យខណ្ឌ ខ នៃកថាខណ្ឌនេះទេ។ ការដកពន្ធបង់មុនលើការបែងចែកភាគលាភ ក្នុងវាក្យខណ្ឌនេះកម្រិតត្រឹម តែពន្ធបង់មុនលើការបែងចែកភាគលាភណាមួយចេញពីប្រាក់ចំណូលដែលកើតឡើងក្នុងឆ្នាំជាប់ពន្ធប៉ុណ្ណោះ។

**ប្រការ៥៣. ការគណនាពន្ធលើប្រាក់ចំណូលត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ**

ពន្ធលើប្រាក់ចំណូលត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅ៖

១- ក្នុងករណីដែលបានគណនាតាមប្រការ៥២ នៃប្រកាសនេះ មានចំនួនច្រើនជាងផលបូកនៃឥណទានពន្ធកាត់ ទុកតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី៩ នៃប្រកាសនេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូល ដែលអ្នកជាប់ពន្ធ បានបង់សម្រាប់ឆ្នាំជាប់ពន្ធតាមមាត្រា ២៨ ថ្មី នៃច្បាប់ស្ដីពីសារពើពន្ធ សហគ្រាសត្រូវបង់បន្ថែមនូវចំនួនលម្អៀងនោះ ជូនរដ្ឋបាលសារពើពន្ធ។

២- ប្រសិនបើការគណនាតាមប្រការ៥២ នៃប្រកាសនេះ មានចំនួនតិចជាងផលបូកនៃឥណទានពន្ធកាត់ទុក តាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី៩ នៃប្រកាសនេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលអ្នកជាប់ពន្ធបាន បង់សម្រាប់ឆ្នាំជាប់ពន្ធតាមមាត្រា ២៨ ថ្មី នៃច្បាប់ស្ដីពីសារពើពន្ធ សហគ្រាសអាចប្រើប្រាស់ចំនួនលម្អៀងជាឥណទាន សម្រាប់កាត់កងទៅនឹងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនៅក្នុងខែបន្ទាប់ពីខែដែលបានដាក់លិខិតប្រកាសពន្ធលើ ប្រាក់ចំណូលប្រចាំឆ្នាំ ឬពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំបន្ទាប់។

៣- មុននឹងធ្វើការទូទាត់ប្រាក់ពន្ធតាមកថាខណ្ឌទី១ នៃប្រការនេះ ឬយោងទៅលើការប្រាក់រំដោះពន្ធលើប្រាក់ចំណូល តាមកថាខណ្ឌ២ នៃប្រការនេះ សហគ្រាសត្រូវតែកំណត់ជាមុននូវបំណុលពន្ធអប្បបរមាក្នុងករណីដែលសហគ្រាសមិនបានទទួលលិខិតបញ្ជាក់ពីការកាន់បញ្ជីកាគណនេយ្យបានត្រឹមត្រូវ ពីអគ្គនាយកដ្ឋានពន្ធដារ។

## ប្រការ៥៤. ការគណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ

ប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចតទៅៈ

១- ពន្ធអប្បបរមាដូចមានចែងក្នុងមាត្រា ២៤ ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវបានបង់នៅពេលធ្វើការទូទាត់ការប្រាក់ ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ពន្ធអប្បបរមាត្រូវបង់សម្រាប់ឆ្នាំជាប់ពន្ធណាមួយអាចត្រូវបានកាត់បន្ថយ ដោយពន្ធលើប្រាក់ ចំណូលដែលបានបង់ជាក់ស្តែងក្នុងឆ្នាំជាប់ពន្ធនោះ។

២- ក្នុងករណីដែលពន្ធលើប្រាក់ចំណូលដែលបានគណនាក្នុងប្រការ៥២ នៃប្រកាសនេះ លើសពីពន្ធអប្បបរមា សហគ្រាសគ្មានទឹកប្រាក់ពន្ធអប្បបរមាត្រូវបង់ទេ ហើយសហគ្រាសត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌ១ និងកថាខណ្ឌ២ នៃប្រការ៥៣ នៃប្រកាសនេះ នៅពេលដាក់លិខិតប្រកាសបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

៣- ក្នុងករណីដែលពន្ធអប្បបរមាលើសពីពន្ធលើប្រាក់ចំណូល ពន្ធអប្បបរមាត្រូវបានកាត់បន្ថយដោយឥណទានពន្ធ របស់សហគ្រាសតាមកថាខណ្ឌ១ នៃប្រការ៥៣ នៃប្រកាសនេះ (គឺផលបូកនៃចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែល សហគ្រាសបានបង់សម្រាប់ឆ្នាំជាប់ពន្ធតាមមាត្រា២៨ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ និងប្រាក់ពន្ធដែលសហគ្រាសដទៃបាន កាត់ទុកតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី៩ នៃប្រកាសនេះ និងឥណទានពន្ធលើប្រាក់ចំណូលយោងពីឆ្នាំមុន ប្រសិន បើមាន) ក្នុងនោះៈ

ក- ប្រសិនបើពន្ធអប្បបរមាច្រើនជាងឥណទានពន្ធតាមកថាខណ្ឌ៣ នៃប្រការនេះ សហគ្រាសត្រូវបង់បន្ថែមនូវ ចំនួនលម្អៀង

ខ- ប្រសិនបើឥណទានពន្ធតាមកថាខណ្ឌ៣ នៃប្រការនេះ ច្រើនជាងពន្ធអប្បបរមា ចំនួនលម្អៀងត្រូវបាន អនុញ្ញាតឱ្យយោងទៅប្រើប្រាស់ជាឥណទានពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ (ប្រាក់រំដោះពន្ធ លើប្រាក់ចំណូល ឬពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ)។

## ប្រការ៥៥. វិធានស្តីពីការយោងការខាតបង់

១- ដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីសារពើពន្ធ ការយោងការខាតបង់ត្រូវបានកំណត់ដូចខាងក្រោមៈ

ក- ការខាតបង់កើតឡើងក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវបានចាត់ជាបន្ទុកនិងត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីប្រាក់ ចំណូលសម្រេចបាននៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់ (ឆ្នាំជាប់ពន្ធទី១ នៃការយោងការខាតបង់)។ ប្រសិនបើប្រាក់ ចំណូលនេះមិនគ្រប់គ្រាន់សម្រាប់ការទូទាត់ជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវ យោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី៥

ខ-ចំនួនកាត់កងក្នុងឆ្នាំជាប់ពន្ធណាមួយត្រូវស្មើនឹងចំនួនប្រាក់ចំណូលដែលសម្រេចបានក្នុងឆ្នាំជាប់ពន្ធនោះដោយមិនត្រូវរក្សាទុកចំណែកណាមួយនៃការខាតបង់សម្រាប់យោងទៅឆ្នាំបន្ទាប់ទៀតឡើយ

គ- នៅពេលណាដែលការខាតបង់មានលើសពីមួយឆ្នាំ បទប្បញ្ញត្តិដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ ត្រូវអនុវត្តចំពោះការខាតបង់ទាំងឡាយ តាមលំដាប់ឆ្នាំដែលការខាតបង់បានកើតឡើង។

២- លក្ខខណ្ឌនៃការអនុញ្ញាតការខាតបង់

ក- ភ័ស្តុតាងបញ្ជាក់ពីការខាតបង់

- ដើម្បីអាចកាត់កងបាន សហគ្រាសត្រូវគណនាការខាតបង់ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារ ហើយការ ខាតបង់នោះបានបំពេញក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដែលបានដាក់ជូនរដ្ឋបាល សារពើពន្ធ
- សហគ្រាសដែលត្រូវទទួលរងការកំណត់ពន្ធជាឯកតោភាគីរបស់រដ្ឋបាលសារពើពន្ធក្នុងឆ្នាំជាប់ពន្ធណា មួយមិនត្រូវបានអនុញ្ញាតឱ្យយោងការខាតបង់ពីឆ្នាំជាប់ពន្ធមុខ មកកាត់កងក្នុងឆ្នាំជាប់ពន្ធដែលមានការ កំណត់ពន្ធជាឯកតោភាគី ឬយោងការខាតបង់ក្នុងឆ្នាំដែលមានការកំណត់ពន្ធជាឯកតោភាគីទៅកាត់កង ទៅឆ្នាំជាប់ពន្ធបន្ទាប់បានទេ។ ចំពោះការខាតបង់ដែលកើតមានមុនឆ្នាំជាប់ពន្ធដែលមានការកំណត់ពន្ធ ជាឯកតោភាគី ត្រូវបានអនុញ្ញាតឱ្យយោងទៅកាត់កងនៅឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមានការ កំណត់ពន្ធជាឯកតោភាគីបាន ប្រសិនបើមិនទាន់ហួសអាយុកាលយោងខាត ៥ឆ្នាំ
- ការខាតបង់ដែលត្រូវបានអនុញ្ញាតឱ្យយកមកកាត់កង ត្រូវតែមានការបញ្ជាក់អះអាងដោយឯកសារនិង បញ្ជីគណនេយ្យស្របតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា និងបានធ្វើនិយ័តកម្មស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារ។

**ខ- អត្តសញ្ញាណនៃសហគ្រាស៖**

- ការខាតបង់របស់សហគ្រាសណាមួយ អាចអនុញ្ញាតឱ្យយោងបានសម្រាប់តែសហគ្រាសនោះប៉ុណ្ណោះក្នុងករណីផ្លាស់ប្តូរសកម្មភាពអាជីវកម្ម ដែលក្នុងនោះជាការបញ្ឈប់សកម្មភាពចាស់ និងចាប់ផ្តើមសកម្មភាពថ្មីទៀត។ ឧទាហរណ៍៖ សហគ្រាសឈប់ធ្វើសកម្មភាពខាងលក់ដូរ មកធ្វើសកម្មភាពខាងការងារ សំណង់...) ការខាតបង់ដែលសហគ្រាសបានទទួលរងក្នុងសកម្មភាពចាស់របស់ខ្លួន មិនត្រូវបានអនុញ្ញាតឱ្យយកមកកាត់ចេញទេ ពីប្រាក់ចំណូលដែលសហគ្រាសសម្រេចបានក្នុងសកម្មភាពថ្មីរបស់ខ្លួន

**គ-ឆ្នាំជាប់ពន្ធដែលត្រូវអនុវត្តការយោងការខាតបង់៖**

- ការខាតបង់ក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវយោងមកកាត់កងជាដាច់ខាតពីលទ្ធផលចំណេញនៃឆ្នាំជាប់ពន្ធបន្តបន្ទាប់ ដោយមិនអនុញ្ញាតឱ្យរំលងឆ្នាំជាប់ពន្ធដែលមានលទ្ធផលចំណេញណាមួយទេ

- ប្រសិនបើដោយមូលហេតុណាមួយ សហគ្រាសមិនបានយោងការខាតបង់ទាំងអស់ ឬយោងតែចំណែកណាមួយទៅកាត់កងនឹងលទ្ធផលចំណេញនៃឆ្នាំជាប់ពន្ធបន្ទាប់ណាមួយ ដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានអនុញ្ញាត ឱ្យកាត់កងការខាតបង់នេះ មិនអាចយោងទៅកាត់កងពីលទ្ធផលចំណេញនៃឆ្នាំជាប់ពន្ធបន្ទាប់ៗ ទៀតបានទេ
- ការយោងការខាតបង់ត្រូវអនុវត្តរៀងៗ គ្នាទៅតាមលំដាប់ឆ្នាំ ដែលការខាតបង់បានកើតឡើងដោយមិនឱ្យលើសពី៥ឆ្នាំ។

### ប្រការ៥៦. អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ មានដូចតទៅ៖

១- ២០ ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយនីតិបុគ្គល។

២- ៣០ ភាគរយចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាតនិងឧស្ម័នធម្មជាតិឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិរួមទាំងព្រៃឈើ រ៉ែ មាសឬត្បូងថ្មមានតម្លៃនានា

៣-០ ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្នុង រយៈពេលលើកលែងពន្ធ

៤-តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គលសហគ្រាសឯកបុគ្គលនិងសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល

### ប្រការ៥៧. ឥណទានពន្ធបរទេស

១-អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់ចំណូលប្រភពបរទេស និងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសម្រាប់កាត់កងពីប្រាក់ពន្ធលើប្រាក់ចំណូលដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែ លុះណាតែមានការបង្ហាញឯកសារបញ្ជាក់ពីការបង់ពន្ធនៅបរទេសនោះ។

២-ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួន សរុបនៃប្រាក់ចំណូលដែលបានទទួលពីប្រភពកម្ពុជានិងប្រភពបរទេសមកគិត។

៣-ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នា សម្រាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅ ប្រទេសក្រៅនីមួយៗ។ ឥណទានពន្ធដែលអនុញ្ញាតឱ្យកាត់កងសម្រាប់ឆ្នាំជាប់ពន្ធ និងសម្រាប់ប្រាក់ពន្ធដែលបានបង់នៅ ប្រទេសក្រៅណាមួយ គឺចំនួនដែលទាបជាងគេក្នុងចំណោម÷

ក- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយនោះ

ខ- ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់ចំណូលជាប់ពន្ធសរុបពីគ្រប់ប្រភពសម្រាប់រយៈពេលជាមួយគ្នា ដែលគណនាតាមអត្រាពន្ធក្នុងមាត្រា ២០ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ទៅគុណនឹងផលចែករវាងប្រាក់ចំណូលជាប់ពន្ធដែលបានទទួលនៅប្រទេសក្រៅនោះនិងប្រាក់ចំណូលជាប់ពន្ធសរុបពីគ្រប់ប្រភព។

៤- ឥណទានពន្ធបរទេសអាចផ្តល់ឱ្យបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទ ព្រមទាំងផ្តល់ ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់អ្នកទូទាត់ប្រាក់ពន្ធនៅបរទេសនិងរដ្ឋបាល សារពើពន្ធបរទេសនោះ។

## ប្រការ៥៨. ពន្ធបង់មុនលើការបែងចែកភាគលាភ

១- អនុលោមតាមមាត្រា ២៣ ថ្មី (ពីរ) នៃច្បាប់ស្តីពីសារពើពន្ធ ប្រសិនបើសហគ្រាសណាមួយមានបែងចែកភាគលាភចេញពីប្រាក់ចំណូលមុនបង់ប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ទៅឱ្យអ្នកចូលហ៊ុនក្នុងស្រុក ឬអ្នកចូលហ៊ុនបរទេសសហគ្រាសនោះត្រូវបង់ពន្ធមុន លើការបែងចែកភាគលាភដែលមានចំនួនស្មើ នឹងផលគុណនៃទឹកប្រាក់ភាគលាភបំប៉ោងទៅតាមអត្រាពន្ធលើប្រាក់ចំណូល គុណនឹងអត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដូចមានចែងក្នុងមាត្រា ២០ ថ្មី (មួយ) នៃច្បាប់ស្តីពី សារពើពន្ធ។

២- ពន្ធបង់មុនលើការបែងចែកភាគលាភ មិនអនុវត្តទេចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែល ស្ថិតក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល។

៣- ប្រាក់ពន្ធដែលបានបង់តាមកថាខណ្ឌ ១ នៃប្រការនេះត្រូវបានអនុញ្ញាតជាឥណទានពន្ធសម្រាប់កាត់កងនឹងពន្ធ លើប្រាក់ចំណូលប្រចាំឆ្នាំជាប់ពន្ធដែលមានការបែងចែក។ ប្រសិនបើ ឥណទានពន្ធមានចំនួនលើសពីប្រាក់ពន្ធលើប្រាក់ ចំណូលប្រចាំឆ្នាំ ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យយោងទៅមុខសម្រាប់កាត់កងនឹងពន្ធលើប្រាក់ចំណូលនៃឆ្នាំជាប់ពន្ធ បន្តបន្ទាប់។

៤- ភាគលាភដែលបានបង់ពន្ធតាមកថាខណ្ឌ១ នៃប្រការនេះនៅពេលបែងចែកបន្ត មិនត្រូវជាប់ពន្ធបង់មុនលើការ បែងចែកភាគលាភទៀតទេ។

៥- ពន្ធបង់មុនលើការបែងចែកភាគលាភដូចមានចែងក្នុងប្រការនេះ មិនអនុវត្តទេចំពោះប្រាក់ចំណូលពីបុព្វលាភ ធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រា ២១ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

៦- ឧទាហរណ៍៖ ក្នុងខែតុលា ឆ្នាំ២០២០ សហគ្រាសមួយបានបែងចែកប្រាក់ចំណូលនៃឆ្នាំចរន្តចំនួន ៤០ ០០០ ០០០ រៀល ទៅឱ្យម្ចាស់ភាគហ៊ុននៃសហគ្រាសនោះ។ ដូចនេះ សហគ្រាសត្រូវប្រកាសបង់ពន្ធបង់មុនលើការបែងចែកភាគលាភ សម្រាប់រយៈពេលជាប់ពន្ធខែតុលា ឆ្នាំ២០២០ នូវចំនួនដូចខាងក្រោម៖

❖រូបមន្តបំប៉ោងសម្រាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ២០%

$$\text{ភាគលាភមុនបង់ពន្ធ} = \frac{\text{ភាគលាបដែលបានទទួល}}{១ - \frac{២០}{១០០}\ (\text{អត្រាពន្ធ})} = \frac{\text{ភាគលាបដែលបានទទួល}}{០,៨}$$

= ៤០ ០០០ ០០០ ÷ ០,៨ = ៥០ ០០០ ០០០រៀល

ពន្ធបង់មុនលើការបែងចែកភាគលាភ = ៥០ ០០០ ០០០ x២០% = ១០ ០០០ ០០០រៀល

### ៣.២.៣ ការដាក់ស្នើលិខិតប្រកាសពន្ធ

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយស និងសូមជម្រាបជូនដំណឹងដល់ស្ថាប័នពាក់ព័ន្ធលោក-លោកស្រីជាអភិបាលបណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងលោក-លោកស្រី ជាប្រធានសមាគម និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងបរទេសទាំងអស់ ឱ្យបានជ្រាបថា កន្លងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ ចេញនូវសេចក្តីណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ គ្រប់គ្រង ការដាក់លិខិតប្រកាសពន្ធតាម អនឡាញ (E-Filing) និងទម្រង់លិខិតប្រកាសពន្ធប្រចាំខែថ្មី សម្រាប់អ្នកជាប់ពន្ធសម្រាប់ដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែ។អគ្គនាយកដ្ឋានពន្ធដារបានអភិវឌ្ឍរួចរាល់ នូវប្រព័ន្ធគ្រប់គ្រងការដាក់លិខិត ប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ តាមអនឡាញ (Tol E-Filing) ដើម្បីសម្រួលដល់ការដាក់លិខិត ប្រកាសនិងបង់ប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដើម្បីពង្រឹងសេវាផ្នែកចាត់ចែងលិខិតប្រកាសពន្ធជូនអ្នកជាប់ពន្ធ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ស័ក្តិសិទ្ធិភាពជានាបាននូវតម្លាភាព ភាពងាយស្រួល ឆាប់រហ័សចំណេញពេលវេលានិងភាពជឿទុកចិត្ត ក្នុងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធ។

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមប្រព័ន្ធ គ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tol E-Filing) ចាប់ពីខែមីនា ឆ្នាំ ២០២១ នេះតទៅ ដោយត្រូវអនុវត្តតាមបែបបទ និងនីតិវិធី ដូចខាងក្រោម ៖

**១. សម្រាប់អ្នកជាប់ពន្ធមធ្យម និងធំ**

អ្នកជាប់ពន្ធមធ្យម និងធំទាំងអស់ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដោយប្រើប្រាស់ប្រព័ន្ធ គ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tol E-Filing) ក្នុងរយៈពេល ៣ ខែ ក្រោយ ពីដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ។

**១.១ ការចូលប្រើប្រាស់ប្រព័ន្ធ Tol E-Filing**

អ្នកប្រើប្រាស់ដែលមានគណនី និង ធ្លាប់ប្រើប្រាស់ប្រព័ន្ធ E-Filing ដើម្បីបង់ពន្ធប្រចាំខែរួចហើយមិនតម្រូវឱ្យចុះឈ្មោះប្រើប្រាស់ឡើងវិញទេ ដោយគ្រាន់តែចូលប្រើប្រាស់កម្មវិធីគណនីដែលមានស្រាប់ដូចធ្លាប់ចូលប្រើ ប្រាស់ប្រព័ន្ធ E-Filing ប្រចាំខែនេះ។ ដោយឡែក ចំពោះអ្នកប្រើប្រាស់ទាំងឡាយណា ដែលពុំទាន់មានគណនីត្រូវចុះឈ្មោះប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ តាមអនឡាញ (Tol E-Filing) ដោយត្រូវចូលទៅកាន់គេហទំព័រ ដែលមានអាសយដ្ឋាន https://www.tax.gov.kh

ដើម្បីចុះឈ្មោះបង្កើតគណនី (User Account) សម្រាប់ប្រើប្រាស់ប្រព័ន្ធ ដោយត្រូវវាយបញ្ចូលព័ត៌មានដូចខាងក្រោម៖

- ព័ត៌មានបុគ្គលរបស់អ្នកប្រើប្រាស់
- លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកប្រើប្រាស់
- លេខសម្គាល់ការចុះបញ្ជីព័ត៌មានបុគ្គល (TID) ប្រសិនបើមាន

-ជ្រើសរើសប្រភេទអ្នកប្រើប្រាស់រួមមាន អ្នកជាប់ពន្ធ អ្នកតំណាងក្រុមហ៊ុន ឬភ្នាក់ងារសេវាកម្មពន្ធដារ (ត្រូវបំពេញលេខអាជ្ញាប័ណ្ណ សម្រាប់ភ្នាក់ងារសេវាកម្មពន្ធដារ) លេខទូរស័ព្ទ និងអ៊ីម៉ែល ដែលបានផ្តល់នៅពេលចុះបញ្ជីពន្ធដារ និងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ របស់អគ្គនាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទឬអ៊ីម៉ែលត្រូវបានផ្លាស់ប្តូរ លោក-លោកស្រី ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។

**១.២ នីតិវិធីលម្អិតក្នុងការប្រើប្រាស់ប្រព័ន្ធ Tol E-Filing**

បន្ទាប់ពីបានចុះឈ្មោះបង្កើតគណនី (User Account) សម្រាប់ប្រើប្រាស់ហើយ ឬមានគណនីដែលបានបង្កើតរួចស្រាប់ អ្នកប្រើប្រាស់អាចចូលក្នុងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធ លើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ(Tol E-Filing) បានដោយត្រូវអនុវត្តតាមនីតិវិធីលម្អិត ដូចខាងក្រោម៖

+ចូលទៅគេហទំព័រដែលមានអាស័យដ្ឋាន https://www.tax.gov.kh ដោយប្រើប្រាស់គណនីដែលបានបង្កើតរួច ដោយត្រូវជ្រើសរើសយកប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ តាមអនឡាញ (Tol E-Filing)

+បន្ទាប់មក បង្កើតពាក្យស្នើសុំប្រកាសពន្ធនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដើម្បីបញ្ចូលព័ត៌មាន សហគ្រាសដែលត្រូវប្រកាសដូចខាងក្រោម៖

+លេខអត្តសញ្ញាណកម្មសារពើពន្ធ (VATIN)

+លេខប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ (Tax Registration Identification Card) នៅលើប័ណ្ណប្លាស្ទិកដែលអគ្គនាយកដ្ឋានពន្ធដារផ្តល់ជូនលោក-លោកស្រី

+លេខទូរស័ព្ទដែលបានផ្តល់នៅពេលចុះបញ្ជីពន្ធដារ ហើយត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ(ក្នុងករណីលេខទូរស័ព្ទត្រូវបានផ្លាស់ប្តូរ លោក-លោកស្រី ដែលត្រូវបានធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។ អគ្គនាយកដ្ឋានពន្ធដារ នឹងមិនទទួលខុសត្រូវចំពោះការបញ្ចូល ព័ត៌មានលេខទូរស័ព្ទខុសរបស់អ្នកប្រើប្រាស់ឡើយ ហើយករណីបញ្ចូលខុសអ្នកប្រើប្រាស់នឹង មិនអាចចូលប្រើប្រាស់ប្រព័ន្ធបានឡើយ

+បញ្ចូលព័ត៌មាននៃប្រតិបត្តិការរបស់សហគ្រាសជាបន្តបន្ទាប់ តាមលំហូរដែលមានក្នុងប្រព័ន្ធនីមួយៗ ពីទំព័រទី១ ដល់ទំព័រទី១៦ (ដូចមានក្នុងឧបសម្ព័ន្ធ TOI 01) តាមចំណុចលម្អិត

+ផ្ទៀងផ្ទាត់ទិន្នន័យ និងចុចប៊ូតុងបង្កើតពាក្យស្នើសុំប្រកាសពន្ធ និងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ រួចចុចបញ្ជូន (Submit) ក្នុងការបង់ប្រាក់ពន្ធ អ្នកជាប់ពន្ធអាចមានជម្រើសដូចខាងក្រោម៖

→ ក្នុងករណីអ្នកជាប់ពន្ធបង់ប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅធនាគារ អ្នកជាប់ពន្ធត្រូវបោះពុម្ពពាក្យ ស្នើសុំប្រកាសពន្ធ និងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ (ដូចមានក្នុងឧបសម្ព័ន្ធ TOI 01-A) ដើម្បីទៅ

បង់ប្រាក់ពន្ធនៅតាមបញ្ជរទទួលប្រាក់ពន្ធនៅរដ្ឋបាលសារពើពន្ធ ឬនៅតាមធនាគារជាដៃគូដែលបានចុះ អនុស្សរណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

→ ក្នុងករណីអ្នកជាប់ពន្ធបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ (E-Payment) អ្នកជាប់ពន្ធអាចជ្រើសរើសគណនីធនាគារជាដៃគូ ដែលបានចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់លោក លោកស្រី (ដូចមានក្នុងឧបសម្ព័ន្ធ TOI O1-C) និងបង់ពន្ធហើយបោះពុម្ពបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ (ដូចមានក្នុងឧបសម្ព័ន្ធ TOI 01-B)

អ្នកជាប់ពន្ធពុំចាំបាច់ យកលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ និងពាក្យស្នើសុំបង់ប្រាក់ពន្ធមកដាក់នៅរដ្ឋបាលសារពើពន្ធនោះទេ ដោយគ្រាន់តែបោះពុម្ពលិខិតបញ្ជាក់ការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូល ប្រចាំឆ្នាំចំនួន១៦ ទំព័រ និងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ ដើម្បីទុកជាឯកសារ និងត្រូវរក្សាទុកឯកសារនានាដែល ពាក់ព័ន្ធនឹងការដាក់លិខិតប្រកាសនេះ ដើម្បីបង្ហាញជូនរដ្ឋបាលសារពើពន្ធ នៅពេលដែលត្រូវបានស្នើសុំត្រួតពិនិត្យ ឬធ្វើសវនកម្មពន្ធដារ។

## ២. សម្រាប់អ្នកជាប់ពន្ធតូច

អ្នកជាប់ពន្ធតូចអាចដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ដោយប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់ អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) ក្នុងរយៈពេល ៣ ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ។ ក្នុងករណី អ្នកជាប់ពន្ធតូចមិនទាន់អាចបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលតាមកម្មវិធីនេះបានអាចបំពេញលិខិតប្រកាសពន្ធដោយដៃ និងដាក់លិខិតប្រកាសពន្ធនៅរដ្ឋបាលសារពើពន្ធបាន។

### ២.១. ការទាញយក និងចូលប្រើប្រាស់កម្មវិធី

អ្នកប្រើប្រាស់ដែលមានគណនី និងធ្លាប់ប្រើប្រាស់កម្មវិធីខាងលើ ដើម្បីបង់ពន្ធប្រចាំខែរួចហើយមិនតម្រូវឱ្យចុះឈ្មោះប្រើប្រាស់ឡើងវិញទេ ដោយគ្រាន់តែចូលប្រើប្រាស់គណនីដែលមានស្រាប់ ដូចធ្លាប់ចូលប្រើប្រាស់កម្មវិធីនេះ។ ដោយឡែក ចំពោះអ្នកប្រើប្រាស់ទាំងឡាយណាដែលពុំទាន់មានគណនី ត្រូវចុះឈ្មោះប្រើប្រាស់ដោយចូលទៅទាញយក កម្មវិធីបានតាម App Store (សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ (IOS) ឬទាញយកពី Play Store (សម្រាប់អ្នក ប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ Android) ដោយស្វែងរកពាក្យ GDT Tax Prefiling App និងត្រូវវាយបញ្ចូលព័ត៌មានមួយចំនួនដូចខាងក្រោម៖

- ព័ត៌មានបុគ្គលរបស់អ្នកប្រើប្រាស់
- លេខអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកប្រើប្រាស់
- លេខសម្គាល់ការចុះបញ្ជីព័ត៌មានបុគ្គល (TID) ប្រសិនបើមាន
- ជ្រើសរើសប្រភេទអ្នកប្រើប្រាស់ រួមមាន អ្នកជាប់ពន្ធ អ្នកតំណាងក្រុមហ៊ុន ឬភ្នាក់ងារសេវាកម្មពន្ធដារ (ត្រូវបំពេញលេខអាជ្ញាប័ណ្ណ សម្រាប់ភ្នាក់ងារសេវាកម្មពន្ធដារ) លេខទូរស័ព្ទ និងអ៊ីម៉ែលដែល

បានផ្តល់នៅពេលចុះបញ្ជីពន្ធដារ និងត្រូវបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ (ក្នុងករណីលេខទូរស័ព្ទ និងអ៊ីម៉ែលត្រូវបានផ្លាស់ប្តូរ លោក-លោកស្រី ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានដើម្បីផ្លាស់ប្តូរលេខទូរស័ព្ទ)។

### ៣. ការបំពេញលិខិតប្រកាសពន្ធដោយដៃ

អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធតូច ដែលមិនទាន់អាចប្រើប្រាស់ប្រព័ន្ធនេះបាន អាចស្នើសុំមករដ្ឋបាលសារពើពន្ធ ដើម្បីបំពេញលិខិតប្រកាសពន្ធដោយដៃ និងដាក់លិខិតប្រកាសពន្ធនៅរដ្ឋបាលសារពើពន្ធជាបណ្តោះអាសន្នបាន។ អ្នកជាប់ពន្ធដែលងាចស្នើសុំបំពេញលិខិតប្រកាសពន្ធដោយដៃបាន គឺអាចបញ្ជូនលិខិតប្រកាសពន្ធ និងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធមករដ្ឋបាលសារពើពន្ធ តាមរយៈប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ ដោយអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងសេចក្តីណែនាំលេខ៧៧០៥ អពដ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ (ដូចមានក្នុងឧបសម្ព័ន្ធ -សេចក្តីណែនាំលេខ៧៧០៥ អពដ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០)។

ដើម្បីឈ្វេងយល់បន្ថែមអំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ តាមអនឡាញ ( ToI E-Filing) និងកម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) អ្នកប្រើប្រាស់ អាចពិនិត្យមើលលម្អិតក្នុងសៀវភៅណែនាំស្តីពីការប្រើប្រាស់ របស់អគ្គនាយកដ្ឋានពន្ធដារ ដែលមាននៅលើគេហទំព័រ https://www.tax.gov.kh ឬចូលទស្សនាវីដេអូណែនាំ ឬ អាចទូរស័ព្ទមក Call Center 1277 ឬចូល ជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទ ដែចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថាស្ថាប័នពាក់ព័ន្ធ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាស និងលោក-លោកស្រីជាប្រធានសមាគមនិងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងបរទេសទាំងអស់ នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ គ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ(ToI E-Filing) ដើម្បីធ្វើការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំឆ្នាំឱ្យបានត្រឹមត្រូវ និងទទួលបាននូវប្រសិទ្ធភាពខ្ពស់។

#### ៣.២.៤ ការបង់ប្រាក់ពន្ធ

បុគ្គលជាប់អាករ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ និងបង់ប្រាក់អាករលើការស្នាក់នៅជារៀងរាល់ខែយ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់សម្រាប់ការដាក់លិខិតប្រកាសសារពើពន្ធផ្ទាល់ ឬយ៉ាងយូរត្រឹមថ្ងៃទី២៥ នៃខែបន្ទាប់សម្រាប់ការដាក់លិខិតប្រកាសសារពើពន្ធតាមអនឡាញ (E-Filing សម្រាប់អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំ និងកម្មវិធី GDT Tax Prefiling App សម្រាប់អ្នកជាប់ពន្ធតូច)។

ចំពោះការបង់ពន្ធអ្នកជាប់ពន្ធ អាចបង់នៅតាមបណ្តាលសាខាធានាគារពាណិជ្ជដៃគូ របស់អគ្គនាយកដ្ឋានពន្ធដារ ឬតាមប្រព័ន្ធបង់ប្រាក់ពន្ធតាមអនឡាញ e-Payment សម្រាប់អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំ ឬGDT Tax Prefiling App សម្រាប់អ្នកជាប់ពន្ធតូច។

### ៣.២.៥ អ្នកជាប់ពន្ធត្រូវអនុវត្តន៍ច្បាប់

ក្រៅពីនេះអគ្គនាយកដ្ឋានពន្ធដារ អាចអនុវត្តន៍ការត្រួតពិនិត្យទៅលើអ្នកបង់ពន្ធ ដើម្បីធានាថាអ្នកជាប់ពន្ធមានទំនួលខុសត្រូវតាមប្រកាស និងការបង់ពន្ធ។ ក្នុងករណីមានការបំពានច្បាប់អំពីពន្ធ អ្នកបង់ពន្ធអាចនឹងរងការទណ្ឌកម្ម ឬផាកពិន័យស្របនឹងច្បាប់ពន្ធដារ។

➢ **មាត្រា២២៣ ការធ្វេសប្រហែសបទប្បញ្ញត្តិទូទៅ**

អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែស ប្រសិនបើប្រាក់ពន្ធបានបង់មានចំនួនតិចជាងប្រាក់ពន្ធ ដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារមិនលើសពី១០(ដប់) ភាគរយ ឬមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានកំណត់។

➢ **មាត្រា២២៤ ការធ្វេសប្រហែសធ្ងន់ធ្ងរ**

អ្នកជាប់ព័ន្ធឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែសធ្ងន់ធ្ងរ ប្រសិនបើប្រាក់ពន្ធបានបង់មានចំនួនតិចជាងប្រាក់ពន្ធ ដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារលើសពី១០( ដប់ )ភាគរយ។

➢ **មាត្រា២៣៣ ពន្ធបន្ថែមនិងការប្រាក់**

• ពន្ធបន្ថែមនិងការប្រាក់ត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះបុគ្គលដែលប្រព្រឹត្តអំពើធ្វេសប្រហែសដូចមានចែងក្នុងមាត្រា២២៣ នៃច្បាប់នេះប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង១០( ដប់ )ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ ឬបង់យឺតបូកបន្ថែមការប្រាក់១,៥( មួយក្បៀសប្រាំ) ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់។

២- ចំពោះបុគ្គលដែលប្រព្រឹត្តអំពើធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុង មាត្រា២២៤ នៃច្បាប់នេះប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង២៥( ម្ភៃប្រាំ )ភាគរយនៃចំនួនប្រាក់ពន្ធ ដែលបង់ខ្វះបូកបន្ថែមការប្រាក់ ១,៥( មួយក្បៀសប្រាំ )ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។

៣-ក្នុងករណីការកំណត់ពន្ធជាឯកតោភាគី ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង៤០( សែសិប )ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់១,៥( មួយក្បៀសប្រាំ )ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ សម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។

៤- ក្នុងករណីការកំណត់ពន្ធជាឯកតោភាគីចំពោះការមិនដាក់លិខិតប្រកាស ប្រាក់ពន្ធបន្ថែម ត្រូវ ស្មើនឹង៤០ ( សែសិប )ភាគរយនៃចំនួនប្រាក់ពន្ធដែលបានកំណត់ បូកបន្ថែមការប្រាក់១,៥( មួយក្បៀសប្រាំ ) ភាគរយនៃចំនួនប្រាក់ពន្ធដែលបានកំណត់សម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធមិនទាន់បានបង់។

៥- ប្រសិនបើបុគ្គលមិនបានបង់ពន្ធក្នុងរយៈពេល១៥( ដប់ប្រាំ )ថ្ងៃ ក្រោយពេលបានទទួលលិខិត ជូនដំណឹងរំលឹកការទារបំណុលពន្ធ ពន្ធបន្ថែមត្រូវកំណត់តាមអត្រា២៥( ម្ភៃប្រាំ )ភាគរយនៃទឹកប្រាក់ពន្ធ បង់យឺត បូកនឹងការប្រាក់១,៥( មួយក្បៀសប្រាំ )ភាគរយនៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់។

៦- ពន្ធបន្ថែមចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងពន្ធប្រថាប់ត្រាត្រូវស្មើនឹង១០០ ភាគរយនៃប្រាក់ពន្ធត្រូវបង់។

៧- ការប្រាក់ដូចមានចែងក្នុងមាត្រានេះ ត្រូវគិតចាប់ពីថ្ងៃទី១ នៃខែបន្ទាប់ពីខែដែលត្រូវបង់ពន្ធ។ ចំពោះពន្ធលើប្រាក់ចំណូល ការប្រាក់ត្រូវគិតចាប់ពីថ្ងៃទី១នៃខែបន្ទាប់ដែលជាខែផុតរយៈពេលកំណត់ សម្រាប់ការដាក់លិខិតប្រកាសលទ្ធផលប្រចាំឆ្នាំ។ ការប្រាក់មិនត្រូវអនុវត្តទេ ក្នុងរយៈពេលកំណត់ពន្ធ ឡើងវិញតាមមាត្រា ២១១នៃច្បាប់នេះ ឬក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយការប្រគល់លិខិត ជូនដំណឹងទារបំណុលពន្ធ តាមមាត្រា២១៣នៃច្បាប់នេះ។

## ៣.៣ សារៈសំខាន់នៃការប្រមូលពន្ធលើប្រាក់ចំណូល




### ៣.៣.១ អត្ថប្រយោជន៍នៃការប្រមូលពន្ធលើប្រាក់ចំណូល

ការរួមចំណែកនៃពន្ធលើប្រាក់ចំណូលសម្រាប់ការអភិវឌ្ឍន៍ជាតិរួមមាន៖

### ក. ចំណាយទូទៅនៃសង្គមកិច្ចនិងអភិវឌ្ឍ

+ ពន្ធជាប្រភពចំណូលដ៏សំខាន់ដើម្បីទ្រទ្រង់ និង ដំណើរការរដ្ឋទាំងមូល ៖

- បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ មន្ត្រី កម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តន៍ជន
- ពន្ធដែលប្រមូលបានគឺ សម្រាប់ចំណាយទៅលើ គ្រឿងឧបករណ៍ គ្រឿងសង្ហារឹម សម្ភារៈការិយាល័យនៅតាមក្រសួងមន្ទីរ ស្ថាប័ន និងអង្គភាពចំណុះឲ្យរដ្ឋ ។
- ប្រាក់ពន្ធដែលប្រមូលបានគឺសម្រាប់ចំណាយទៅលើហេដ្ឋារចនាសម្ព័ន្ធសង្គមដូចជា៖ ផ្លូវថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ ជាដើម ។
- ប្រាក់ពន្ធក៏ត្រូវបានចំណាយទៅលើវិស័យសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងវិស័យការពារជាតិ ។

### ខ. សម្រាប់សេដ្ឋកិច្ចជាតិ

- អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារការរៀបចំនិងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់
- ពលរដ្ឋ មានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី

●រដ្ឋរក្សាការពារបរិស្ថាន និងគុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាតនិងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើនិងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល។

● រដ្ឋយកចិត្តទុកដាក់នឹងជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផលជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល។

●រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានកម្រិតសមរម្យ។

●រដ្ឋជំរុញការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ ដាច់ស្រយាល ដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយពីភជញ្ជូន បច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន។

### គ. ចំណាយទៅលើវិស័យអប់រំ និងសុខាភិបាល

●ការសិក្សា អប់រំចំណេះដឹងទូទៅដោយមិនបង់ប្រាក់តាមព្យាបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ។

●រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ និងព្យាបាលជំងឺ

●ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យព្យាបាលដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាននិង មន្ទីរសម្ភពសាធារណៈ។

●រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និងមន្ទីរសម្ភពដល់ជនបទ

●រដ្ឋយកចិត្តទុកដាក់ ចំពោះកុមារនិងមាតា។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារី ដែលមានកូនច្រើនក្នុងបន្ទុកហើយឥតទីពឹង។

●រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជន ដែលបានបូជាជីវិត ដើម្បីប្រទេសជាតិ។

### ៣.៣.២ លទ្ធផលសរុបពីការប្រមូលពន្ធលើប្រាក់ចំណូល

យោងតាមរបាយការណ៍សាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្ហាញថា ក្នុងឆ្នាំ២០២៣ ប្រទេសកម្ពុជា បានប្រមូលពន្ធលើប្រាក់ចំណូលសរុបស្មើនឹង១.៨ ពាន់លានដុល្លារអាមេរិកដែលជាអត្រាកើនឡើងប្រហែល៨% បើប្រៀបធៀបទៅនឹងឆ្នាំ២០២២។ ចំណូលពន្ធលើប្រាក់ចំណូលនេះ បានកាន់កាប់សមភាពប្រមាណជាង៥០% នៃចំណូលសរុបដែលអគ្គនាយកដ្ឋានពន្ធដារបានប្រមូលបានក្នុងឆ្នាំនោះ។ អត្រានេះ បង្ហាញពីសារៈសំខាន់នៃពន្ធលើប្រាក់ចំណូល ក្នុងការផ្គត់ផ្គង់ថវិកាជាតិ និងគាំទ្រគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល។

# ជំពូកទី៤
# វិភាគទៅលើចំណុចខ្លាំងចំណុចខ្សោយ

# ជំពូកទី៤
# វិភាគទៅលើចំណុចខ្លាំងនិងចំណុចខ្សោយ

## ៤.១ ការវិភាគទៅលើចំណុចខ្លាំង

ក្រោយពីបានសិក្សាស្រាវជ្រាវអំពីប្រធានបទដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារនៅខាងលើរួមមកយើងបានយល់ច្បាស់អំពីដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលក្នុងនោះដែលយើងសង្កេតឃើញថាមានចំណុចខ្លាំងជាច្រើនចំណុចរួមមានដូចខាងក្រោម៖

- អគ្គនាយកដ្ឋានពន្ធដារបានចាត់វិធានការពង្រឹង ការអនុវត្តច្បាប់កាត់បន្ថយនូវការគេចវេះពន្ធ ឱ្យបានជាអតិបរមា
- អគ្គនាយកដ្ឋានពន្ធដារអនុវត្តការត្រួតពិនិត្យ និងធ្វើសវនកម្មទៅលើអ្នកជាប់ពន្ធ ដើម្បីធានាថាអ្នកបង់ពន្ធមានការប្រកាស និងបានបង់ប្រាក់ពន្ធត្រឹមត្រូវ
- អគ្គនាយកដ្ឋានពន្ធដារ សហការជាមួយអង្គភាពក្រោមឱវាទ និងស្ថាប័ននានា ដើម្បីធ្វើការរៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលដែលជម្រុញដល់ការអភិវឌ្ឍសមត្ថភាពមន្ត្រីក្នុងការប្រមូលព័ត៌មានអ្នកជាប់ពន្ធ
- អគ្គនាយកដ្ឋានពន្ធដារ ចាត់ចំណាត់ថ្នាក់ អ្នកជាប់ពន្ធតូចនិងមធ្យម ត្រូវកំណត់តាមកម្រិតផលរបរ និងទ្រព្យសកម្ម មានការបែងចែកដោយផ្អែកលើ វិស័យអាជីវកម្ម ដូចជា កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងពាណិជ្ជកម្ម
- អគ្គនាយកដ្ឋានពន្ធដារមានវិធានគណនេយ្យ សមស្របតាមទំហំអាជីវកម្ម សម្រាប់អ្នកជាប់ពន្ធតូចប្រើវិធានគណនេយ្យសាមញ្ញ សម្រាប់អ្នកជាប់ពន្ធមធ្យម និងធំត្រូវប្រើវិធានគណនេយ្យតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ
- ដំណើរការនេះ ត្រូវបានរៀបចំយ៉ាងមានប្រព័ន្ធស្របច្បាប់ និងមានតម្លាភាព ដើម្បីបង្កើតក្របខណ្ឌច្បាប់ សេដ្ឋកិច្ច និងរដ្ឋបាលដែលធានាថាការប្រមូលពន្ធធ្វើឡើងដោយស្មើភាព មានភាពច្បាស់លាស់ និងគ្មានអំពើពុករលួយ

## ៤.២ ការវិភាគទៅលើចំណុចខ្សោយ

ការប្រមូលពន្ធជាឧបករណ៍សំខាន់មួយ សម្រាប់រដ្ឋក្នុងការរកចំណូល ដើម្បីប្រើប្រាស់សម្រាប់ការចំណាយសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយប្រព័ន្ធនេះ ក៏មានចំណុចខ្សោយដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងថវិការនិងសេដ្ឋកិច្ចជាតិ។ចំណុចខ្សោយរួមមានដូចខាងក្រោម៖

- ខ្វះការវិភាគលម្អិតពីផលប៉ះពាល់ពិតប្រាកដ ការបញ្ចេញវិធានការបន្ថយអត្រាពន្ធ ដើម្បីទាក់ទាញការ វិនិយោគប៉ុន្តែមិនបង្ហាញថា វាមានឥទ្ធិពលយ៉ាងដូចម្តេចលើប្រាក់ចំណូលពន្ធ, សេដ្ឋកិច្ចក្នុងស្រុក ឬការបាត់បង់ប្រាក់ចំណូលរដ្ឋ។

•ភាពងាយរងឥទ្ធិពលពីសេដ្ឋកិច្ចជាសកល ប្រទេសកម្ពុជាក៏រងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចអន្តរជាតិនៃការរីករាលដាលនៃជំងឺកូវីត-19(COVID-19)ទាមទារឲ្យមានការកាត់បន្ថយពន្ធដើម្បីលើកស្ទួយសេដ្ឋកិច្ចប៉ុន្តែមានផលប៉ះពាល់ដល់ស្ថិរភាពថវិកាជាតិ។

•ការខាតបង់ចំណូលពន្ធរដ្ឋអាចប៉ះពាល់ដល់ជំនួយឧបត្ថម្ភអាជីវកម្មតូចនិងមធ្យមបើរដ្ឋមានចំណូលពន្ធថយចុះ អាចធ្វើឲ្យមានកាត់បន្ថយកម្មវិធីលើកទឹកចិត្ត ឬជំនួយសេដ្ឋកិច្ចសម្រាប់អាជីវកម្មតូចនិងមធ្យម។

•ពន្ធដារខិតខំរឹតបន្តឹងទប់ស្កាត់ទៅលើការគេចវេះពន្ធយ៉ាងណាក៏ដោយក៏នៅមានចំណុចធ្វេសប្រហែសមួយចំនួនដូចជា ការគេចវេះមិនបង់ពន្ធ ការពន្យាពេលការបង់ពន្ធ និងការបង់ពន្ធ មិនត្រឹមត្រូវតាមច្បាប់។

ដោយសារតែចំណុចខ្សោយទាំងនេះ ប្រាក់ពន្ធដែលគេប្រមូលបានអាចមិនអាចឆ្លើយតបទៅនឹងតម្រូវការរបស់សង្គម និងសេដ្ឋកិច្ចបានយ៉ាងគ្រប់គ្រាន់។ ដូច្នេះ រដ្ឋត្រូវមានយុទ្ធសាស្ត្រសមរម្យ ដើម្បីកែលម្អប្រព័ន្ធពន្ធឲ្យមានប្រសិទ្ធភាព ការតម្លាភាព និងភាពយុត្តិធម៌សម្រាប់ប្រជាជនទាំងមូល។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

សរុបជារួមមក យោងទៅតាមការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារយើងយល់ឃើញថា គោលដៅរបស់ពន្ធដាគឺជាការបង្កើនប្រសិទ្ធភាពក្នុងការប្រមូលពន្ធដើម្បីពង្រឹងសេដ្ឋកិច្ចនិងបម្រើសង្គម។ វាមិនត្រឹមតែជាវិធីសាស្រ្តសម្រាប់ការប្រមូលពន្ធលើប្រាក់ចំណូលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាឧបករណ៍មួយដែលសំខាន់សម្រាប់ការជំរុញការវិនិយោគ ការបង្កើតការងារនិងការបង្កើនសុភមង្គលរបស់ប្រជាពលរដ្ឋ។ រីឯតួនាទីរបស់ពន្ធដារ ដែលសំខាន់ក្នុងការរួមបញ្ចូលមានការបង្កើតប្រភពចំណូលថវិការឱ្យរដ្ឋជួយជម្រុញល្បឿន ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចទប់ស្កាត់សម្រួលចំណូលរបស់ប្រជាពលរដ្ឋនៅក្នុងសង្គម។ ដើម្បីទប់ស្កាត់សម្រួលចំណូលនិងការបែងចែកឡើងវិញ នូវចំណូលរវាងបណ្តាលស្រទាប់វណ្ណៈផ្សេងៗគ្នានៅក្នុងសង្គម។ ជាទូទៅរាជរដ្ឋាភិបាលបានបង្កើតពន្ធប្រយោលចំពោះប្រភេទទំនិញ ឬសេវាមួយចំនួនចំពោះសញ្ញាណាដែលចំណូលខ្ពស់ជំនួសឲ្យការយកពន្ធដោយផ្ទាល់។

## ៥.២ ការផ្តល់អនុសាសន៍

អំពីការផ្តល់អនុសាសន៍លើដំណើរការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារដើម្បីពង្រឹងប្រសិទ្ធភាព នៃដំណើរការប្រមូលពន្ធលើប្រាក់ចំណូលអគ្គនាយកដ្ឋានពន្ធដារ គួរតែពិចារណា អនុវត្តន៍អនុសាសន៍សំខាន់ៗដូចជា៖

- រដ្ឋាភិបាលគួរតែធ្វើការពង្រឹង និងអភិវឌ្ឍន៍ទៅលើប្រពន្ធ័បច្ចេកវិទ្យាព័ត៌មាន ក៏ដូចជាកម្មវិធីផ្សេងៗ ដែលគ្រប់គ្រងក្នុងការប្រមូលពន្ធលើប្រាក់ចំណូល និងការបង់ពន្ធនានាឱ្យកាន់តែប្រសើរឡើង
- ដើម្បីឱ្យមន្រ្តីពន្ធដារមានភាពងាយស្រួល ក្នុងការត្រួតពិនិត្យនិងតាមដានការបង់ពន្ធលើប្រាក់ចំណូលរបស់អ្នកជាប់ពន្ធឱ្យបានច្បាស់លាស់និងងាយស្រួលដល់អ្នកជាប់ពន្ធមិនចំណាយពេលវេលាយូក្នុងការបង់ពន្ធ
- អគ្គនាយកដ្ឋានពន្ធដារត្រូវជម្រុញការងារដល់មន្រ្តីពន្ធដារលើផ្នែកសេវាកម្ម និងការផ្តល់ព័ត៌មានអំពីការបង់ប្រាក់ពន្ធនិងជួយរកដំណោះស្រាយសម្រាប់អតិថិជនក្នុងការបង់ពន្ធជូនរដ្ឋ
- គួរតែលើកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធលើប្រាក់ចំណូល ដើម្បីជួយដល់រដ្ឋាភិបាលក្នុងការប្រមូលពន្ធឱ្យបានគ្រប់ចំនួន
- មន្រ្តីពន្ធដារគួរតែមានការផ្សព្វផ្សាយ ពន្យល់ណែនាំដល់ប្រជាពលរដ្ឋទូទៅឱ្យស្វែងយល់អំពីការប្រមូលពន្ធលើប្រាក់ចំណូលកាន់តែទូលំទូលាយ
- ពង្រឹងការអប់រំពន្ធដល់សាធារណៈជនការផ្តល់អប់រំ និងការចូលរួមផ្សព្វផ្សាយអំពីសារៈសំខាន់នៃការបង់ពន្ធគួរតែត្រូវបានធ្វើបន្ថែម ជាពិសេសចំពោះអាជីវកម្មតូចនិងជនរួមសហគមន៍។ នេះអាចជួយបង្កើនការយល់ដឹងនិងកាត់បន្ថយការបំពានច្បាប់ពន្ធ។
- អភិវឌ្ឍបច្ចេកវិទ្យាឌីជីថលបន្តពង្រឹងប្រព័ន្ធបង់ពន្ធតាមអនឡាញ និងប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយ ដើម្បីធ្វើឲ្យដំណើរការបង់ពន្ធ មានភាពងាយស្រួល ស្វ័យប្រវត្តិ និងកាត់បន្ថយការលំបាកសម្រាប់អ្នកបង់ពន្ធ។

# ឯកសារយោង

# ឯកសារយោង


- អគ្គនាយកដ្ឋានពន្ធដារ. *សេចក្តីប្រកាសពន្ធលើប្រាក់ចំណូលឆ្នាំ២០២៣.* ទំព័រទី៤ ប្រការ៧
- រៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (ឆ្នាំ២០២២). *សៀវភៅឈ្មោះផ្ទាល់ធុរកិច្ច.* Retrieved from https://business.gov.kh/
- អគ្គនាយកដ្ឋានពន្ធដារ. (ថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣). *ពន្ធលើប្រាក់ចំណូល.* Retrieved from https://www.tax.gov.kh/km/content-detail/ab8WB7716349947443
- អគ្គនាយកដ្ឋានពន្ធដារ. (ឆ្នាំ២០២៣). *សៀវភៅច្បាប់ស្តីពីសារពើពន្ធ.* ទំព័រទី១៧
- អគ្គនាយកដ្ឋានពន្ធដារ. (ឆ្នាំ២០២៣). *ច្បាប់ស្តីពីសារពើពន្ធ.*ទំព័រទី៦. មាត្រាទី៦
- អគ្គនាយកដ្ឋានពន្ធដារ. ច្បាប់ពន្ធនៅកម្ពុជា. *មេរៀនទី១ ការណែនាំអំពីពន្ធដារ.* ទំព័រ៣
- Facebook page. រតនាភិរុណ. (2024, February18). *ពិភពគណនេយ្យ.* Retrieved from https://www.facebook.com/100032074736268/posts
- KHsearch. Khem Sarith (2019, May 19). *Finance and Accounting Education*
- សន ស៊ីថន. (2012 October 19). *សៀវភៅចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច.ស.វ.ក).* Retrieved from https://nis.gov.kh/nis/CSIC/CSIC_V1_KH%2081012.pdf


- Facebook page. រតនាភិរុណ. (2024, February18). *ពិភពគណនេយ្យ.* Retrieved from
https://www.facebook.com/100032074736268/posts

# ឧបសម្ព័ន្ធ

# ច្បាប់

# ស្តីពី

# សារពើពន្ធ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ..០៩៥......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ពន្ធលើប្រាក់ចំណូល

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798